ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

# សទ្ទានុក្រម
# វិទ្យាសាស្ត្រនយោបាយ និង ការទូត
## ខ្មែរ-អង់គ្លេស-បារាំង

# LEXICON OF POLITICAL SCIENCE AND DIPLOMACY
## Khmer-English-French

ក្រុមប្រឹក្សាជាតិភាសាខ្មែរ
គណៈកម្មការវិទ្យាសាស្ត្រនយោបាយ

មិថុនា ២០១៤

អាសយដ្ឋាន: មហាវិថីសហព័ន្ធរុស្ស៊ី, សង្កាត់កាកាប, ខណ្ឌពោធិ៍សែនជ័យ, រាជធានីភ្នំពេញ
ទូរសព្ទដៃ: (៨៥៥) ១២ ៩១១ ៣៥៧ / (៨៥៥) ១២ ៩០៦ ៥៨៥, អ៊ីមែល: info@nckl.gov.kh, គេហទំព័រ: www.nckl.gov.kh

# បុព្វកថា

ពាក្យមួយចំនួនក្នុងសទ្ទានុក្រមនេះ ជាពាក្យទាក់ទងនឹងការទូត ជាពាក្យដែលមន្ត្រីជាន់ខ្ពស់ធ្លាប់ប្រើតរបតមកហើយ ដូច្នេះ ទាំងអត្ថន័យ ទាំងអក្ខរាវិរុទ្ធ មិនចោទជាបញ្ហាទេ : ការចុះផ្សាយបច្ចេកសព្ទទាំងនេះក្នុងសទ្ទានុក្រមនេះ គ្រាន់តែជំនួយដល់សាធារណជនណាដែលអាចមានការស្រពេចស្រពិលម្តងម្កាល។

ក្រៅពីពាក្យការទូត មានពាក្យនៃវិទ្យាសាស្ត្រនយោបាយ ដែលជាពាក្យនៅមិនទាន់មានអត្ថន័យនិងអក្ខរាវិរុទ្ធរតរបតចំពោះអ្នកប្រើប្រាស់គ្រប់គ្នានៅឡើយ។ សទ្ទានុក្រមនេះអាចជួយឲ្យមានឯកភាពក្នុងការប្រើប្រាស់ជាទូទៅនូវពាក្យទាំងនេះ។

សទ្ទានុក្រមនៃបច្ចេកសព្ទរបស់វិទ្យាសាស្ត្រនយោបាយនិងការទូត ដែលក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.) រៀបចំផ្សព្វផ្សាយនេះ ជាឧបករណ៍ថ្នាក់ជាតិមួយសម្រាប់ជួយសាធារណជនឲ្យប្រើពាក្យក្នុងអត្ថន័យឲ្យបានដូចគ្នា។

សូមអ្នកស្រឡាញ់ភាសាជាតិ ជួយសហការប្រើសទ្ទានុក្រមនេះឡើង ដើម្បីឲ្យភាសាជាតិយើងដើរឆ្ពោះទៅរកឯកភាពនិងរបៀបរៀបរយ ដូចតន្តិភាសាទាំងឡាយក្នុងលោក។

រាជធានីភ្នំពេញ, ថ្ងៃទី 24 ខែ ០៥ ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និង ជាប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ**

បណ្ឌិតសភាចារ្យ **សុខ អាន**

# **អារម្ភកថា**

ពាក្យទាក់ទងនឹងវិទ្យាសាស្ត្រនយោបាយ ដែលមានក្នុងសទ្ទានុក្រមនេះត្រូវបានបោះពុម្ពផ្សាយតាមព្រឹត្តិបត្រម្ដងហើយ ប៉ុន្តែព្រឹត្តិបត្រទាំងនោះត្រូវបានចែកផ្សព្វផ្សាយតែក្នុងមជ្ឈដ្ឋានថ្នាក់ដឹកនាំក្រសួងនានា មន្ទីរអប់រំខេត្ត ការិយាល័យអប់រំស្រុក/ខណ្ឌ នាយកសាលា...។ ម្យ៉ាងទៀត ដើម្បីឲ្យក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.)ងាយអនុម័តពាក្យទាំងនោះ គណៈកម្មការវិទ្យាសាស្ត្រនយោបាយត្រូវផ្ដល់ពាក្យគន្លឹះជាមុន ទោះពាក្យគន្លឹះនោះកើតចេញពីអក្សរណាក៏ដោយ ដើម្បីឲ្យងាយពន្យល់ពាក្យពាក់ព័ន្ធ។ ក្នុងសទ្ទានុក្រមនេះ ពាក្យដែលមានភាពរប៉ាត់រប៉ាយក្នុងព្រឹត្តិបត្រត្រូវបានស្រង់មកតម្រៀបតាមលំដាប់អក្ខរក្រម។

ម្យ៉ាងទៀត ក.ជ.ភ.ខ.សូមបញ្ជាក់ថា សទ្ទានុក្រមនេះត្រូវបានបោះពុម្ពដោយថវិកាបានពីសប្បុរសជន ពីព្រោះថវិកានេះជាប្រាក់សាច់ដែលអាចឲ្យការបោះពុម្ពមានតម្លៃទាប និង ឲ្យងាយស្រួលបង្វិលយកមកបោះសទ្ទានុក្រមនេះឡើងវិញ ឬ សទ្ទានុក្រមនៃជំនាញផ្សេងទៀត ក្រោយពីការដាក់លក់នៅភ្នំពេញនិងនៅគ្រប់ខេត្តបានបញ្ចប់។ សទ្ទានុក្រមជាមធ្យោបាយផ្សព្វផ្សាយទីពីររបស់យើងបន្ទាប់ពីព្រឹត្តិបត្រនិងគេហទំព័រ ហើយ យើងសង្ឃឹមថា មធ្យោបាយនេះអាចផ្សព្វផ្សាយបានទូលំទូលាយជាងមធ្យោបាយមុនៗនៅក្នុងប្រទេសកម្ពុជា។

ក.ជ.ភ.ខ.សូមបញ្ជាក់ថា ថវិកាសម្រាប់បោះពុម្ពសទ្ទានុក្រមនេះមានទឹកប្រាក់តិចតួចណាស់បើយើងប្រៀបធៀបនឹងថវិកាដែលរដ្ឋបានផ្ដល់ឲ្យក.ជ.ភ.ខ.ដើម្បីដំណើរការ។ ថវិកាយ៉ាងច្រើននេះយើងមិនអាចទទួលបានឡើយ បើគ្មានការយកចិត្តទុកដាក់ខ្ពស់ចំពោះក.ជ.ភ.ខ.ពីសំណាក់សម្ដេចបណ្ឌិតសភាចារ្យ អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាគុរុគណនៃក.ជ.ភ.ខ. និង ពីសំណាក់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រីនិងជាប្រធានកិត្តិយសនៃក.ជ.ភ.ខ.។

អាស្រ័យហេតុនេះ ក្នុងនាមក.ជ.ភ.ខ.ទាំងមូល ខ្ញុំសូមថ្លែងអំណរគុណព្រមទាំងកតញ្ញូតាយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំខាងលើ ដែលជាអាណាព្យាបាលនៃក.ជ.ភ.ខ.យើង ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។

រាជធានីភ្នំពេញ, ថ្ងៃ ពុធ ទី 28 ខែ ឧសភា ឆ្នាំ២០១៤

**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

បណ្ឌិតសភាចារ្យ **ជួរ ម៉ល់**

# សមាជិក
# គណៈកម្មការវិទ្យាសាស្ត្រនយោបាយ

| | |
|---|---|
| ១- លោកបណ្ឌិត សុខ ទូច | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិត អ៊ុំ ប៊ុម | អនុប្រធាន |
| ៣- ឯកឧត្តមបណ្ឌិតសភាចារ្យ រស់ ចន្ត្រាបុត្រ | ទីប្រឹក្សា |
| ៤- លោកបណ្ឌិត គិន ភា | សមាជិក |
| ៥- ឯកឧត្តម សូត្រ សំណាង | សមាជិក |
| ៦- លោក ឯម សុវណ្ណរ៉ា | សមាជិក |
| ៧- លោក សាន លាង | សមាជិក |
| ៨- លោក ហុង វណ្ណៈ | សមាជិក |
| ៩- លោកស្រី ហេង ដារី | សមាជិក |
| ១០- លោកបណ្ឌិត យង់ ពៅ | សមាជិក |
| ១១- លោកស្រី គឹម កែវកល្យាណ | សមាជិក |
| ១២- លោក ព្រុំ ពិសាល | សមាជិក |

**រៀបចំបោះពុម្ពផ្សាយដោយ ៖**

ផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្តុះបណ្តាល
នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

# បច្ចេកសព្ទវិទ្យាសាស្ត្រនយោបាយ និង ការទូត
# ដែល
# គណៈកម្មាធិការជាតិភាសាខ្មែរ / គ.ជ.ភ.ខ.
# (បច្ចុប្បន្ន ក្រុមប្រឹក្សាជាតិភាសាខ្មែរ / ក.ជ.ភ.ខ.)
# បានអនុម័ត

| | |
|---|---|
| **១- កតិកាសញ្ញា**<br>អ. pact<br>បារ. pacte ( m. ) | កិច្ចព្រមព្រៀងមួយដែលត្រូវបានធ្វើឡើងរវាងភាគីពីរឬច្រើនឬរវាងរដ្ឋនិងរដ្ឋ ទាំងផ្លូវការ ទាំងមិនផ្លូវការ ដើម្បីធ្វើអ្វីមួយរួមគ្នាក្នុងគោលបំណងបម្រើផលប្រយោជន៍រវាងគ្នាទៅវិញទៅមក។<br>ឧ. នៅក្នុងអំឡុងសង្គ្រាមលោកលើកទី២ ( ១៩៣៩-១៩៤៥ ) ប្រទេសអាល្លឺម៉ង់ អ៊ីតាលីនិងជប៉ុនបានចុះកតិកាសញ្ញាមួយមានឈ្មោះថា "កតិកាសញ្ញា រ៉ូម ប៊ែរឡាំង តូក្យូ" ដើម្បីប្រមូលកម្លាំងយោធាគ្នាប្រឆាំងនឹងសហរដ្ឋអាម៉េរិក អង់គ្លេស បារាំងនិងសហភាពសូវៀត។ |
| **២- កម្លាំងនយោបាយ**<br>អ. political force<br>បារ. force politique ( f. ) | ការស្តែងចេញឱ្យឃើញជាសាធារណៈនូវឫទ្ធានុភាពឬសន្ទុះខាងនយោបាយ ទាំងរូបី ទាំងអរូបី។<br>ឧ. ការហែក្បួនមានមនុស្សដ៏ច្រើនកុះករគគ្រឹកគគ្រេង នៅក្នុងការឃោសនាបោះឆ្នោតគឺជាការបង្ហាញឱ្យឃើញពីកម្លាំងនយោបាយរបស់គណបក្សណាមួយ។ |

| | |
|---|---|
| **៣- កលិយុគនយោបាយ**<br>អ. political trouble<br>បា. trouble politique<br>(f.) | ស្ថានភាពចលាចលជ្រួលច្របល់រីករវខាងផ្នែកនយោបាយដែលបង្កឱ្យមានបញ្ហាអស្ថិរភាពយ៉ាងធ្ងន់ធ្ងរនៅក្នុងសង្គម។<br>ឧ. កលិយុគនយោបាយសម័យលង្វែកក្នុងរជ្ជកាលព្រះសត្ថាទី១ដែលបង្កដោយទំនាស់នយោបាយក្នុងព្រះរាជវង្សានុវង្សនិងបញ្ហាសាសនា។ |
| **៤- ការកសាងសន្តិភាព**<br>អ. peace building<br>បារ. recherché (f.)<br>de la paix | ដំណើរការការងារឆ្ពោះទៅរកវត្ថុបំណងរក្សាសន្តិភាពរួមគ្នានៃគូបដិបក្ខនិងពិភពលោក។<br>ឧ. ការមិនរីកសាយអាវុធប្រល័យលោកគឺជាមាគ៌ាឆ្ពោះទៅរកការកសាងសន្តិភាព។ |
| **៥- ការកាត់សេចក្តី**<br>**ឧក្រិដ្ឋកម្មសង្គ្រាម**<br>អ. war crimes trials<br>បារ. procès (m.)<br>de crime (m.)<br>de guerre (f.) | ការកាត់សេចក្តីចំពោះអំពើទាំងឡាយណាដែលត្រូវបានគេចោទប្រកាន់ទៅលើបទរំលោភច្បាប់សង្គ្រាមនិងទំនៀមទម្លាប់សង្គ្រាមធ្ងន់ធ្ងរ និង គោលការណ៍នៃច្បាប់អន្តរជាតិ។<br>ឧ. ខែវិច្ឆិកា ឆ្នាំ១៩៩៤ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានអនុម័តសេចក្តីសម្រេចចិត្តលេខ៩៥៥ បង្កើតសាលាជម្រះក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់កាត់ទោសនៅប្រទេសរវ៉ាន់ដា។ សាលាជម្រះក្តីនេះមានសិទ្ធិអំណាចកាត់ទោសបុគ្គលទាំងឡាយណាដែលទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍និងអំពើរំលោភបំពានធ្ងន់ធ្ងរនៃច្បាប់មនុស្សធម៌អំឡុងសង្គ្រាមស៊ីវិល ឆ្នាំ១៩៩៤ ក្នុងប្រទេសរវ៉ាន់ដា។ |

| | |
|---|---|
| **៦- ការត្រួតពិនិត្យ ព័ត៌មាន**<br>អ. information control<br>បារ. contrôle ( m. ) des informations ( f. ) | ការអង្កេតនិងតាមដានខ្លឹមសារព័ត៌មានដែលប្រព័ន្ធផ្សព្វផ្សាយទាំងអស់របស់រដ្ឋនិងឯកជនដោយផ្អែកលើច្បាប់និងក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានរបស់ប្រទេសនីមួយៗ។<br>ឧ. នាពេលបច្ចុប្បន្ននេះ ប្រព័ន្ធផ្សព្វផ្សាយនៅប្រទេសមួយចំនួនស្ថិតនៅក្រោមការគ្រប់គ្រងនិងការត្រួតពិនិត្យព័ត៌មានពីរដ្ឋយ៉ាងតឹងរ៉ឹង។ |
| **៧- ការទូត**<br>អ. diplomacy<br>បា. diplomacie ( f. ) | ទំនាក់ទំនងផ្លូវការរវាងរដ្ឋ និង រដ្ឋ ក្នុងគោល-បំណងភ្ជាប់ទំនាក់ទំនងការងារជាមួយគ្នា ដូចជាការស្វែងរកសន្តិភាព ពាណិជ្ជកម្ម សង្គ្រាម សេដ្ឋកិច្ច និង វប្បធម៌ ជាដើម។ មុខងារចម្បងរបស់ការទូតគឺការចរចាដើម្បីបង្ហាញនូវផលប្រយោជន៍ទូទៅរបស់រដ្ឋមួយ ឬ តួអង្គមិនមែនរដ្ឋ ដូចជា អង្គការអន្តរជាតិ និង ដើម្បីដោះ-ស្រាយជម្លោះអ្វីមួយដែលកើតមាននៅក្នុងទំនាក់ទំនងអន្តរជាតិ។<br>ឧ. សង្គ្រាមស៊ីវិលនៅកម្ពុជាដែលអូសបន្លាយជិតពីរទសវត្សរ៍ត្រូវបានបញ្ចប់តាមរយៈការប្រើប្រាស់នូវនយោបាយការទូតរបស់គូភាគីបដិបក្ខនៅក្នុងជម្លោះ ដែលរួមមានភាគីរដ្ឋកម្ពុជា ភាគីកម្ពុជាប្រជាធិបតេយ្យ( ហ៊្វុនស៊ិនប៉ិច ខ្មែរក្រហម និង រណសិរ្សរួបរួមជាតិរំដោះប្រជាពលរដ្ឋខ្មែរ ) ហើយ ជាលទ្ធផលនៃនយោបាយការទូតនេះ |

| | |
|---|---|
| | ភាគីទាំងអស់បានឈានដល់កិច្ចព្រមព្រៀងសន្តិភាពមួយដែលធ្វើឡើងនៅទីក្រុងប៉ារីសចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ដើម្បីបញ្ចប់ជម្លោះនៅកម្ពុជា។ |
| **៨- ការបង្រួបបង្រួមជាតិ**<br>អ. national reconciliation<br>បារ. réconciliation nationale ( f. ) | ការបង្រួបបង្រួមភាគីផ្សេងៗដែលមាននិន្នាការនិងមនោគមវិជ្ជានយោបាយខុសគ្នា ឬ ការបែកបាក់គ្នារបស់ជាតិមួយឱ្យរួបរួមគ្នាឡើងវិញដោយតម្កល់ផលប្រយោជន៍និងបញ្ហាជាតិជាធំ។<br>ឧ. កិច្ចព្រមព្រៀងក្រុងប៉ារីស នាឆ្នាំ១៩៩១ គឺជាលទ្ធផលនៃការបង្រួបបង្រួមខ្មែរច្រើនភាគីដើម្បីបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជាដែលអូសបន្លាយជាងពីរទសវត្សរ៍។ |
| **៩- ការបណ្តេញចេញពីអំណាច**<br>អ. overthrow from a position of power by force<br>បារ. chute ( f. ) du pouvoir ( m. ) par une contrainte | ការបង្ខំនរណាម្នាក់ឬក្រុមណាមួយឱ្យចេញពីតំណែង មុខងារ តួនាទី ក្នុងគណបក្សនយោបាយ ឬ ស្ថាប័នរដ្ឋ ពីព្រោះពួកគេបានបាត់បង់ជំនឿទុកចិត្តពីក្រុមឬស្ថាប័នរបស់ខ្លួនឬដោយសារតែពួកគេមិនគោរពតាមលក្ខខណ្ឌច្បាប់និងគោលការណ៍ផ្សេងៗនៃក្រុមរបស់ខ្លួន។<br>ឧ. នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សម្តេចព្រះ នរោត្តម សីហនុ ត្រូវបានសេនាប្រមុខ លន់ នល់និងអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីមតៈ បានធ្វើរដ្ឋប្រហារបណ្តេញចេញពីអំណាចដោយសារព្រះអង្គត្រូវបានគេចោទប្រកាន់ថា |

| | |
|---|---|
| | មិនអាចគ្រប់គ្រងស្ថានភាពនយោបាយនិងវិបត្តិសេដ្ឋកិច្ចនៅពេលនោះបាន។ |
| **១០- ការបោះឆ្នោតជាកញ្ចប់**<br>អ. bloc voting<br>បារ. vote bloqué ( m. ) | ការបោះឆ្នោតដើម្បីអនុម័តឬសម្រេចបញ្ហាជាច្រើន ក្នុងពេលតែមួយ ដោយសមាជិកម្នាក់ប្រើសន្លឹកឆ្នោតឬសំឡេងតែមួយ។ នីតិវិធីនេះត្រូវបានដកស្រង់ពីរដ្ឋធម្មនុញ្ញប្រទេសបារាំងយកមកកែច្នៃទៅតាមបរិបទនយោបាយកម្ពុជា ដែលអ្នកនយោបាយខ្មែរយកមកប្រើក្រោយពីជាប់គាំងនយោបាយពីឆ្នាំ២០០៣ រហូតដល់ខែកក្កដា ឆ្នាំ២០០៤។<br>ឧ. ក្រោយការបោះឆ្នោតសកលជ្រើសរើសតំណាងរាស្ត្រឆ្នាំ២០០៣ គណបក្សប្រជាជនកម្ពុជាជាប់ឆ្នោតបាន៧៣អាសនៈ គណបក្សហ៊្វុនស៊ិនប៉ិចបាន២៦អាសនៈ និង គណបក្សសម រង្ស៊ី បាន២៤អាសនៈ។ យោងតាមចំនួននេះ គ្មានគណបក្សណាមួយមានសំឡេងគ្រប់ចំនួនពីរភាគបី ដើម្បីបង្កើតរដ្ឋាភិបាលតែម្នាក់ឯងបានទេ។ តាមច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ការបោះឆ្នោតជ្រើសរើសប្រធាននិងអនុប្រធានរដ្ឋសភា ក៏ដូចជាជ្រើសរើសនាយករដ្ឋមន្ត្រីត្រូវការសំឡេងគាំទ្រពីរភាគបី ទើបអាចជ្រើសតាំងបាន ហើយ ដោយសារគណបក្សហ៊្វុនស៊ិនប៉ិច |

| | |
|---|---|
| | និង គណបក្ស សម រង្ស៊ី បានបង្កើតសម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យដែលមិនព្រមឱ្យគណបក្សណាមួយចូលជាមួយគណបក្សប្រជាជនកម្ពុជា ដើម្បីបង្កើតរដ្ឋាភិបាល( បើចូល ចូលទាំងអស់គ្នា  បើចេញ ចេញទាំងអស់គ្នា )។ ស្ថានភាពនយោបាយក៏ត្រូវបានកកស្ទះ។ ក្រោយមកដំណោះស្រាយចំពោះភាពទ័លច្រកបានចេញរួច ដោយគណបក្សហ្វ៊ុនស៊ិនប៉ិចព្រមចូលរួមបង្កើតរដ្ឋាភិបាលចម្រុះជាមួយគណបក្សប្រជា-ជនកម្ពុជា។<br>ការជ្រើសតាំងប្រធានសភា និង រដ្ឋាភិបាលអាណត្តិទី៣ តាមច្បាប់រដ្ឋធម្មនុញ្ញ តំណាងរាស្ត្រត្រូវបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធាននិងគណៈកម្មការនានាជាមុនសិន។ ក្រោយពីបោះឆ្នោតនេះហើយ ទើបបោះឆ្នោតជ្រើសនាយករដ្ឋមន្ត្រីចេញពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា។ តែដោយការបាត់ជំនឿទុកចិត្តលើគណបក្សដៃគូ  គេបានធ្វើវិសោធកម្មរដ្ឋធម្មនុញ្ញដោយបញ្ចូលការបោះឆ្នោតជាកញ្ចប់ដើម្បីសម្រេចបញ្ហាពីរក្នុងពេលតែមួយ។ |
| **១១- ការបោះបង់ តំណែង** | ការដើរចេញឬការលាឈប់ពីមុខដំណែងដោយសារមូលហេតុផ្សេងៗ ដូចជា ការមិនពេញ |

| | |
|---|---|
| អ. abandonment of a position<br>បារ. abandon ( m. ) d'une position/ fonction | ចិត្តនឹងការងារ ទំហំការងារហួសពីសមត្ថភាព ឬ រងសម្ពាធនយោបាយណាមួយ។<br>ឧ.បន្ទាប់ពីទទួលជ័យជម្នះលើរបបសាធារណ-រដ្ឋខ្មែរ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥មក របបកម្ពុជាប្រជាធិបតេយ្យ ដែលមានសម្តេច-ព្រះ នរោត្តម សីហនុ ជាព្រះប្រមុខរដ្ឋ បានចាប់ផ្តើមឡើងកាន់កាប់អំណាច នៅប្រទេសកម្ពុជា ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ប៉ុន្តែ នៅឆ្នាំ១៩៧៦ ព្រះអង្គបានសម្រេចព្រះទ័យ បោះបង់អំណាចជាព្រះប្រមុខរដ្ឋចោល។<br>ឧ. ក្រោមការដឹកនាំរបស់លោកប្រធានាធិបតី បូរីស យែលស៊ីន ពីឆ្នាំ១៩៩១ដល់ឆ្នាំ២០០០ សហព័ន្ធរុស្ស៊ីបានជួបប្រទះនូវវិបត្តិនយោបាយ និងសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ។ មូលហេតុដែលធ្វើឱ្យមានវិបត្តិទាំងនេះគឺ ដោយសារការផ្តាច់ខ្លួនរបស់ប្រទេសចំនួន១៥ចេញពីសហភាពសូវៀត បញ្ហានយោបាយនៅអឺរ៉ុបខាងកើត ការដួលរលំជញ្ជាំងប៊ែរឡាំង ការដកកងទ័ពរុស្ស៊ីចេញពីអាហ្វហ្គានីស្ថាន និង ការផ្ទុះសង្គ្រាមមួយនៅឆេឆេនី។ ដូច្នេះហើយ ដោយមិនអាចដោះស្រាយវិបត្តិទាំងអស់នេះបាន លោកប្រធានា-ធិបតី បូរីស យែលស៊ីន បានបោះបង់តំណែងរបស់ខ្លួនជាប្រធានាធិបតី ដោយផ្ទេរអំណាច |

| | |
|---|---|
| | ទៅឱ្យលោក ប្លាឌីមា ពូទីន គ្រប់គ្រងអំណាចជំនួសវិញ ហើយ រង់ចាំរហូតដល់មានការបោះឆ្នោតសាជាថ្មី។<br>ឲ. ក្រោយពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនីតិកាលទី៣ រដ្ឋាភិបាលចម្រុះមួយត្រូវបានបង្កើតឡើង ដែលក្នុងនោះ គណបក្សប្រជាជនកម្ពុជានិងគណបក្សហ៊្វុនស៊ិនប៉ិច  បានព្រមព្រៀងគ្នាធ្វើជាដៃគូក្នុងការដឹកនាំរដ្ឋាភិបាលរហូតដល់ចប់អាណត្តិ។ ប៉ុន្តែ ក្រោយមកដោយសារគណបក្សប្រជាជន និង គណបក្សសម រង្ស៊ីបានឯកភាពគ្នាធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដោយកែប្រែមាត្រានៃរដ្ឋធម្មនុញ្ញស្តីពីការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តបង្កើតរដ្ឋាភិបាលដោយសំឡេងពីរភាគបីមកនៅត្រឹមតែសំឡេងហាសិបបូកមួយនេះ គណបក្សហ៊្វុនស៊ិនប៉ិនក៏លែងជាដៃគូសំខាន់នៅក្នុងការអនុម័តច្បាប់និងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញទៀតហើយគឺចំណុចនេះហើយដែលជាគំនាបនយោបាយធ្វើឱ្យសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ បោះបង់តំណែងជាប្រធានរដ្ឋសភាអាណត្តិទី៣មុនពេលចប់អាណត្តិ។ |
| **១២- ការរក្សាសន្តិភាព**<br>អ. peace keeping | ការរក្សាសន្តិភាពកើតចេញមកពីការដោះស្រាយរវាងគូប្រឈមពីរឬច្រើនក្រុម ហើយ ចែកជាពីរប្រភេទ ៖ |

| | |
|---|---|
| បារ. maintien (m.) de la paix | ទី១. សំដៅលើភាគីកងកម្លាំងប្រដាប់អាវុធពីរដែលប្រឈមមុខគ្នា ហើយបានឯកភាពព្រមព្រៀងលើគោលការណ៍សន្តិភាព ការឈប់បាញ់គ្នា ដើម្បីដោះស្រាយរាល់បញ្ហាទាំងឡាយណាដែលប្រឈម។<br>ឧ. ក្រោយពីប្រាសាទព្រះវិហារត្រូវបានដាក់ចូលជាបេតិកភណ្ឌពិភពលោក កាលពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៨ កងទ័ពថៃបានចូលមករំលោភបូរណភាពទឹកដីប្រទេសកម្ពុជា។ បញ្ហានេះបានបង្កើតឱ្យមានការផ្ទុះអាវុធជាច្រើនលើក។ ក្រោយមក ភាគីទាំងពីរបានចរចាគ្នាដើម្បីរក្សាសន្តិភាពរវាងភាគីកងទ័ពកម្ពុជានិងកងទ័ពថៃនៅតាមខ្សែព្រំដែនស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។<br>ទី២. សំដៅលើភាគីកងកម្លាំងប្រដាប់អាវុធច្រើនក្រុមដែលប្រឈមមុខដាក់គ្នា ហើយ បានឯក-ភាពព្រមព្រៀងលើគោលការណ៍សន្តិភាពបញ្ឈប់ការបាញ់គ្នា ដោយយកតួអង្គណាមួយជាអាជ្ញាកណ្តាល។<br>ឧ. ជម្លោះរ៉ាំរ៉ៃជាងពីរទសវត្សរ៍រវាងចតុភាគីកម្ពុជាបានឈានទៅរកកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដោយមានអង្គការសហប្រជាជាតិដើរតួជាអ្នកសម្របសម្រួលក្នុងការដោះស្រាយ។ |

| | |
|---|---|
| **១៣- ការរត់ប្រណាំងសព្វាវុធ**<br>អ. arms race<br>បារ. course ( f. ) aux armements ( m. ) | ការប្រកួតប្រជែងខាងការបង្កើតសព្វាវុធដោយភាគីពីរយ៉ាងតិចដែលប្រឈមគ្នា ដើម្បីឧត្តមភាពខាងគ្រឿងសព្វាវុធ។ ដំណើរការមូលដ្ឋានក្នុងការរត់ប្រណាំងសព្វាវុធនេះគឺសំដៅទៅលើបែបបទនៃប្រតិកម្មឆ្លើយតបរបស់ភាគីដែលប្រកួតប្រជែង។ ជាទូទៅ ការប្រកួតប្រជែងនេះជំរុញឱ្យមានការផ្ទុះឡើងនូវអំពើហិង្សា និងសង្គ្រាម ដូចជាការរត់ប្រណាំងសព្វាវុធរវាងសហភាពសូវៀតនិងសហរដ្ឋអាមេរិកបានធ្វើឱ្យប្រទេសតូចៗនិងប្រទេសជិតខាងជួបប្រទះភាពតានតឹងនិងផ្ទុះសង្គ្រាម។ តែផ្ទុយទៅវិញ ការប្រកួតប្រជែងបែបនេះក៏អាចនាំមកនូវការរីកចម្រើនជាវិជ្ជមានជាច្រើនខាងផ្នែកវិទ្យាសាស្ត្រផងដែរ ជាក់ស្តែងដូចជា ក្នុងសង្គ្រាមលោកលើកទី១ ការរត់ប្រណាំងខាងនាវារវាងចក្រភពអង់គ្លេស និង ចក្រភពអាល្លឺម៉ង់។ |
| **១៤-ការលើកលែងទោស**<br>អ. amnesty<br>បារ. amnistie ( f. ) | ការសម្រេចចិត្តមួយដែលបដិសេធ ( ងាកចេញពី )នីតិវិធីច្បាប់ឬការផ្តន្ទាទោសចំពោះអ្នកប្រព្រឹត្តទោសកំហុសមួយចំនួន ( ជាធម្មតាគឺជាទោសនយោបាយ )។ ការលើកលែងទោសមានន័យប្រហាក់ប្រហែលគ្នាទៅនឹងការអភ័យទោស ប៉ុន្តែគ្មានន័យលាក់កំបាំងនៃការអត់ឱនទោស |

| | |
|---|---|
| | ដែលអនុវត្តជាធម្មតានោះទេ។ ការលើកលែងទោសអាចធ្វើជាទូទៅឬជាផ្នែកជាក់លាក់ពេញលេញឬមិនពេញលេញ។ ពាក្យនេះត្រូវបានគេប្រើជាទូទៅក្នុងទំនាក់ទំនងចំពោះអ្នកទោសសង្គ្រាមនិងអ្នកទោសមនសិការ។ អង្គការលើកលែងទោសអន្តរជាតិ គឺជាអង្គការមិនមែនរដ្ឋាភិបាលដែលយកចិត្តទុកដាក់ចំពោះការមើលខុសត្រូវ(ការពិនិត្យពិច័យ)ទៅលើភាពលម្អៀងយ៉ាងធំធេង នៅលើពិភពលោក លើករណីផ្សេងៗ ដូចជា បុគ្គលម្នាក់ៗឬក្រុមណាមួយ ដែលត្រូវគេផ្តន្ទាទោស ពីព្រោះតែទស្សនៈនយោបាយ និងសាសនារបស់ពួកគេ។ |
| **១៥- ការសម្រុះសម្រួល**<br>អ. accomodation<br>បារ. conciliation (f.) | ដំណើរការដែលធ្វើឱ្យតួអង្គក្នុងទំនាស់ឯកភាពទទួលយកសំណើរបស់ភាគីម្ខាងទៀតដែលមិនប៉ះពាល់ផលប្រយោជន៍មូលដ្ឋានរបស់ពួកគេទាំងសងខាង។ ការសម្រុះសម្រួលត្រូវសន្មតថាជាជម្លោះអន្តរជាតិ មិនមែនដូចនៅក្នុងទ្រឹស្តីល្បែង ឬ ការប្រកួតប្រជែងដែលក្នុងនោះ ភាគីមួយឈ្នះ ហើយ ជាស្វ័យប្រវត្តិ ភាគីម្ខាងទៀតចាញ់នោះទេ។ ការសម្រុះសម្រួលអាចសន្មតថាភាពចុះសម្រុងទាំងស្រុងខាងផលប្រយោជន៍មិនអាចសម្រេចបានទេ។ ដូច្នេះ ការសម្រុះ |

| | |
|---|---|
| | សម្រួលជាចំណុចកណ្តាលនៃបញ្ហាប្រឈមនិងការចុះសម្រុងគ្នា។ ពាក្យនេះ ជាធម្មតាត្រូវបានគេប្រើទាក់ទងនឹងផលប្រយោជន៍ ដូច្នេះមិនមែនគ្មានទឡ្ហីករណ៍ខុសឆ្គង ឬ ការបំភាន់នោះទេ។ |
| **១៦- ការិយាធិបតេយ្យ**<br>អ. bureaucracy<br>បារ. bureaucratie( f. ) | ប្រព័ន្ធរដ្ឋបាលរបស់អង្គភាពមួយដែលតាមរយៈប្រព័ន្ធនេះ ការបែងចែកការងារត្រូវបានរៀបចំជាឋានានុក្រម ដើម្បីអនុវត្តនូវភារកិច្ចជំនាញដោយឈរលើមូលដ្ឋានវិធានផ្ទៃក្នុង និង នីតិវិធីរបស់អង្គភាពនេះ។ ពាក្យនេះត្រូវបានគេប្រើសំដៅទៅលើរដ្ឋបាលរបស់រដ្ឋាភិបាល ជាពិសេសអំពីមន្ត្រីរាជការនៅក្នុងរដ្ឋាភិបាល និង សេវាសាធារណៈផ្សេងៗ។ តាមន័យអវិជ្ជមាន គេតែងប្រើពាក្យនេះដើម្បីសម្គាល់ប្រព័ន្ធរដ្ឋបាលសាំញ៉ាំដែលអនុញ្ញាតឱ្យមន្ត្រីរាជការឆ្លៀតយកអំណាចដែលរដ្ឋប្រគល់ឱ្យ ដើម្បីបម្រើបុព្វសិទ្ធិរបស់ខ្លួនហើយ ដែលធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍របស់អ្នកដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។<br>ឧ. នៅសហរដ្ឋអាម៉េរិក ការិយាធិបតេយ្យនេះបានរីកដុះដាលដែលធ្វើឱ្យខូចប្រយោជន៍របស់វណ្ណៈអធន ហើយ បានដកហូតយកអំណាចពីវណ្ណៈនេះ។ |

| | |
|---|---|
| **១៧- កិច្ចព្រមព្រៀង អន្តរជាតិ**<br>អ. international agreement<br>បារ. accord international ( m. ) | មានន័យដូចសន្ធិសញ្ញាដែរ ប៉ុន្តែមានលក្ខណៈផ្លូវការតិចជាងសន្ធិសញ្ញា។ លក្ខណវិនិច្ឆ័យនៃកិច្ចព្រមព្រៀង គឺ ៖<br>- ត្រូវបានប្រើជាពិសេសសម្រាប់លិខិតូបករណ៍ដែលមានលក្ខណៈបច្ចេកទេសឬរដ្ឋបាល។<br>- កិច្ចព្រមព្រៀងមិនទាមទារឱ្យមានការផ្តល់សច្ចាប័នពីសភាឡើយ។<br>- ក្នុងករណីខ្លះកិច្ចព្រមព្រៀងអាចមិនមានទម្រង់ជាលាយលក្ខណ៍អក្សរ ដូចជា កិច្ចព្រមព្រៀងផ្ទាល់មាត់ដែលអាចជាកិច្ចសន្យា ដែលធ្វើឡើងដោយនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសនៃប្រទេសមួយជាមួយដៃគូរបស់ខ្លួន ឬជាមួយរដ្ឋដទៃទៀត។<br>ឧ. កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មនិងពន្ធគយ ( General Agreement on Trade and Tariff ) ។ |
| **១៨- កុបកម្ម**<br>អ. riot<br>បារ. émeute ( f. ) | ការបះបោរឬចលាចលដោយប្រើអំពើហិង្សាបង្កឡើងដោយមនុស្សមួយក្រុមឬច្រើនក្រុមនៅពេលពួកគេមិនពេញចិត្តទៅលើបញ្ហាណាមួយ។ កុបកម្មអាចកើតចេញពីកូដកម្មឬបាតុកម្ម នៅពេលដែលកូដករឬបាតុករចាប់ផ្តើមប្រែក្លាយការតវ៉ាឬទាមទារដោយសន្តិវិធីទៅជាការតវ៉ាឬទាមទារដោយប្រើអំពើហិង្សា។<br>ឧ. នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣ កុបករបាននាំគ្នាធ្វើកុបកម្មវាយបំផ្លាញស្ថានទូតថៃ។ |

| | |
|---|---|
| **១៩- កុម្មុយនីស្ត**<br>អ. communist<br>បារ. communiste (m.) | គេច្រើនប្រើពាក្យនេះជាគុណនាម ៖ ប្រទេសកុម្មុយនីស្ត របបកុម្មុយនីស្ត។ ប្រទេសកុម្មុយនីស្តជាសង្គម ដែលទ្រព្យផលិតកម្មជាកម្មសិទ្ធិរបស់សមូហភាព ហើយ ប្រព័ន្ធដឹកនាំប្រទេសស្ថិតក្រោមអំណាចផ្តាច់មុខរបស់បក្សកុម្មុយនីស្ត។<br>ឧ. នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩១៧ ប្រទេសរុស្ស៊ីបានធ្វើបដិវត្តន៍ផ្តួលរំលំរបបសក្តិភូមិ ហើយប្តូររបបដឹកនាំប្រទេសទៅជារបបកុម្មុយ-នីស្តវិញ។ |
| **២០- កូដកម្ម**<br>អ. strike<br>បារ. grêve (f.) | ការសម្តែងអាកប្បកិរិយាប្រឆាំងចំពោះរឿង ឬកិច្ចការណាមួយដែលខ្លួនមិនពេញចិត្ត តាមរយៈការមិនចូលរួមបំពេញភារកិច្ចអ្វីមួយ ការមិនចូលធ្វើការ ការដាក់ទណ្ឌកម្មខ្លួនឯង ហើយ ក្នុងករណីខ្លះអាចឈានទៅរកការធ្វើអត្តឃាត។ |
| **២១- កំណត់ទូត**<br>អ. note verbale<br>បារ. note verbale (f.) | ជាលិខិតទាក់ទងផ្លូវការរវាងក្រសួងការបរទេស និងក្រសួងការបរទេសរបស់រដ្ឋនានាឬជាលិខិតទាក់ទងរបស់ស្ថាប័ននៃរដ្ឋមួយជាមួយស្ថានទូតបរទេស នៅក្នុងប្រទេសរបស់ខ្លួន ដើម្បីជាការជូនដំណឹងនិងសហប្រតិបត្តិការផ្សេងៗទៀត។ |
| **២២- ខ្លាអាស៊ី**<br>អ. asian tigers<br>បារ. tigres (m.)<br>d´Asie | ពាក្យនេះជានិមិត្តរូបដែលនិយាយសំដៅទៅរកក្រុមសេដ្ឋកិច្ចអាស៊ីដែលធ្លាប់មានបទពិសោធជឿនលឿនផ្នែកសេដ្ឋកិច្ចយ៉ាងរហ័ស នៅក្នុងអតីតកាលថ្មីៗរបស់ខ្លួននិងត្រូវបានគេចាត់ទុក |

| | |
|---|---|
| | ថា ជាក្រុមគំរូសម្រាប់សេដ្ឋកិច្ចទីផ្សារសេរី និង សេរីនិយមខាងសេដ្ឋកិច្ច។ ជាធម្មតា ក្រុមសេដ្ឋ-កិច្ចអាស៊ីចំនួនប្រាំ ដែលគេស្គាល់ មាន ជប៉ុន កូរ៉េខាងត្បូង សិង្ហបុរី ហុងកុង និង តៃវ៉ាន់។ ប្រទេសដែលគេសន្មតហៅជាទូទៅថា ជាកូនតោ រួមមាន ឥណ្ឌូណេស៊ី ម៉ាឡេស៊ី និង ថៃ។ បន្ទាប់ពីឆ្នាំ១៩៩៧ ប្រទេសចិនដែលរួមបញ្ចូលទាំងហុងកុងផងនោះ គេអាចពណ៌នាប្រដូចទៅនឹងនាគ ហៅថា នាគអាស៊ី ហើយ តាមទស្សនៈខ្លះខ្លាអាស៊ី គេហៅថាជា នាគអាស៊ី វិញ។ |
| **២៣- គោលការណ៍មិនជ្រៀតជ្រែក**<br>អ. non-interference principle<br>បារ. principe ( m. ) de non-ingérence ( f. ) | ជាគោលការណ៍ទូតដែលមិនអនុញ្ញាតឱ្យរដ្ឋមួយមានសិទ្ធិធ្វើអន្តរាគមន៍នៅក្នុងកិច្ចការផ្ទៃក្នុងនៃរដ្ឋមួយទៀត ទាំងផ្នែកនយោបាយ យោធា សេដ្ឋកិច្ច បច្ចេកទេស និង វប្បធម៌។ល។<br>ឧ.នៅឆ្នាំ១៩៧៥ គោលការណ៍មួយនៃសេចក្ដីថ្លែងការណ៍នៅហែលស៊ិនគី បានអនុញ្ញាតឱ្យសហភាពសូវៀតប្រកាសថ្កោលទោសបស្ចិមប្រទេសដែលគាំទ្រអ្នកប្រឆាំងឬអ្នករត់ចោលជួរពីប្រទេសកុម្មុយនីស្ត។ |
| **២៤- គោលនយោបាយការបរទេស**<br>អ. foreign policy<br>បារ. principe ( m. ) de politique étrangère ( f. ) | យុទ្ធសាស្ត្រឬផែនការដែលរៀបចំឡើងដោយអ្នកធ្វើសេចក្ដីសម្រេចរបស់រដ្ឋមួយចំពោះរដ្ឋដទៃទៀតឬនីតិបុគ្គលអន្តរជាតិនានា ដើម្បីសម្រេចបាននូវគោលបំណងជាក់លាក់សម្រាប់ជាតិរបស់ខ្លួន។ គោលដៅនៃនយោបាយការបរទេសមាន |

| | |
|---|---|
| | បីគឺ សន្តិសុខជាតិ សុខុមាលភាពសេដ្ឋកិច្ចនិងអត្តសញ្ញាណជាតិ។ សន្តិសុខជាតិមានន័យថាគឺការការពារអធិបតេយ្យ បូរណភាពទឹកដី, សុខុមាលភាពសេដ្ឋកិច្ច គឺការរីកចម្រើនផ្នែកសេដ្ឋកិច្ច និង អត្តសញ្ញាណជាតិ គឺការការពារវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់។ |
| **២៥- ចក្រពត្តិនិយម**<br>អ. imperialism<br>បារ. impérialisme(m.) | នយោបាយមួយនៃការប្រើអំណាចត្រួតត្រារបស់រដ្ឋមួយទៅលើរដ្ឋដទៃទៀត។ ការត្រួតត្រានេះអាចមានលក្ខណៈជាសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដូចជា ពេលដែលអំណាចចក្រពត្តិនិយមលើកទឹកចិត្តឱ្យមានការរៀបចំដាក់ទុននិងតាំងសហគ្រាសរបស់គេនៅក្នុងប្រទេសមួយផ្សេងទៀតជាដើម ហើយ ទិញមកវិញនូវវត្ថុធាតុដើមក្នុងតម្លៃទាប។ ការត្រួតត្រានេះអាចមានទម្រង់ជាវប្បធម៌ កាលណាប្រទេសមួយយកភាសា ខ្សែភាពយន្ត និង រចនាបថរបស់ខ្លួនទៅផ្សព្វផ្សាយនៅបរទេស ក្នុងគោលបំណងបង្ខំឱ្យទទួលយក។ ចក្រពត្តិនិយមមិនមែនសុទ្ធតែប៉ះពាល់ជាចាំបាច់ដល់ឯករាជ្យនយោបាយនៃប្រទេសដែលគេពង្រីកខ្លួនគេនោះទេ ពីព្រោះប្រទេសទាំងនោះអាចរក្សានូវរដ្ឋាភិបាលរបស់ខ្លួន។<br>ឧ. ជនជាតិរុស្ស៊ីបានពង្រីកឥទ្ធិពលរបស់ខ្លួន |

| | |
|---|---|
| | ទៅលើប្រជាជនស៊ីបេរី តាមរយៈការប្រើនយោបាយចក្រពត្តិនិយមនៅសតវត្សរ៍ទី១៩និងជនជាតិជប៉ុនបានពង្រីកឥទ្ធិពលរបស់ខ្លួននៅប្រទេសចិននៅឆ្នាំ១៩៣៧។ |
| **២៦- ចលនាមិនចូលបក្សសម្ព័ន្ធ**<br>**អ.** non-aligned movement<br>**បារ.** mouvement (m.) des non-alignés (m.) | និន្នាការនយោបាយនៃប្រទេសកំពុងអភិវឌ្ឍមួយចំនួនដែលប្រកាសថាមិនចូលក្នុងប្លុកនយោបាយណាមួយ។<br>ចលនានេះត្រូវបានបង្កើតជាផ្លូវការនៅទីក្រុងបែលក្រាដ(Belgrade) នៅឆ្នាំ១៩៦១ ក្រោមគំនិតផ្ដួចផ្ដើមរបស់ប្រធានាធិបតីយូហ្គោស្លាវី Sosip Broz Tito នាយករដ្ឋមន្ត្រីឥណ្ឌា Jawaharlal Nehru ប្រធានាធិបតីអេហ្ស៊ីប Gama lAbdel Nasser ប្រធានាធិបតីហ្គាណា Kwame Nkrumah ប្រធានាធិបតីឥណ្ឌូណេស៊ី Achmed Sukarno និង អធិរាជអេត្យូពី Haile Selassie។ ចលនានេះមានគោលបំណងធានាឯករាជ្យជាតិ អធិបតេយ្យ បូរណភាពទឹកដី និងសន្តិសុខនៃបណ្ដារដ្ឋជាសមាជិកក្នុងការតស៊ូប្រឆាំងចក្រពត្តិនិយម អាណានិគមនិយម អាណានិគមនិយមបែបថ្មី ការប្រកាន់ពូជសាសន៍និយមនិងរាល់ទម្រង់នៃការឈ្លានពាន ការកាន់កាប់ ការគ្រប់គ្រង ការជ្រៀតជ្រែកឬអនុត្តរភាព |

| | |
|---|---|
| | ក៏ដូចជាការប្រឆាំងនឹងមហាអំណាច និង ប្លុកនយោបាយ។ |
| **២៧- ចៅហ្វាយឡើងបុណ្យ ខុនឡើងសក្តិ** | ការឡើងបុណ្យ ឬ ឥទ្ធិពលតាមរយៈចៅហ្វាយនាយរបស់ខ្លួន។ ជាធម្មតា កាលណាចៅហ្វាយនាយឡើងបុណ្យ ខុនដែលជាមន្ត្រីធ្វើការក្រោមឱវាទតែងតែឡើងសក្តិតាមឋានៈខ្លះៗ ឬ យ៉ាងហោចណាស់ក៏បានទទួលឥទ្ធិពលពីមេខ្លះៗដែរ។ |
| **២៨- ច្បាប់អន្តរជាតិ**<br>អ. internalional law<br>បារ. droit internalional<br>(ក.) | ប្រព័ន្ធនៃវិធានស្តីពីសិទ្ធិនិងភារកិច្ចរបស់រដ្ឋនានានៅក្នុងទំនាក់ទំនងរវាងរដ្ឋទាំងនោះ។ ច្បាប់អន្តរជាតិផ្អែកលើទស្សនាទាននៃសមភាពនិងអធិបតេយ្យរបស់រដ្ឋនានានិងផ្អែកទាំងស្រុងទៅលើការព្រមព្រៀងរវាងរដ្ឋទាំងនោះ។ ម៉្យាងទៀត ច្បាប់អន្តរជាតិគឺជាសំណុំនៃគោលការណ៍និងវិធានដែលគ្រប់គ្រងលើសិទ្ធិនិងភារកិច្ចរបស់រដ្ឋនានា អង្គការអន្តរជាតិនានានិងមនុស្សទូទៅនៅក្នុងទំនាក់ទំនងរបស់ពួកគេនៅលើពិភពលោក។ ច្បាប់អន្តរជាតិផ្តល់នូវមគ្គុទ្ទេសន៍សម្រាប់សកម្មភាពរបស់រដ្ឋជាសមាជិកនិងផ្តល់នូវវិធីសាស្ត្រសម្រាប់ដោះស្រាយជម្លោះរវាងរដ្ឋនានាដោយសន្តិវិធីនិងដោយយោងតាមបទដ្ឋានដែលបានយល់ស្របទាំងអស់គ្នាជាជាងប្រើកម្លាំងបាយ។ |

| | |
|---|---|
| | ជាទូទៅ ច្បាប់អន្តរជាតិមានគោលដៅគ្រប់គ្រងរាល់សកម្មភាពក្នុងទំនាក់ទំនងអន្តរជាតិរវាងរដ្ឋនិងរដ្ឋ ប៉ុន្តែ បច្ចុប្បន្ននេះ ច្បាប់អន្តរជាតិក៏យកចិត្តទុកដាក់កាន់តែខ្លាំងឡើងទៅលើបុគ្គលនានាផងដែរ ជាពិសេស ការប្រព្រឹត្តរបស់រដ្ឋទៅលើបុគ្គលឬក៏សកម្មភាពបុគ្គលទៅលើរដ្ឋ។ ដូច្នេះហើយ ទាំងបុគ្គល ក៏ដូចជាប្រទេសនានាមានកាតព្វកិច្ចនិងសិទ្ធិនៅក្រោមច្បាប់អន្តរជាតិនានា។<br>២. ចំពោះប្រទេសជាសមាជិកនៃអង្គការសហប្រជាជាតិ គេមានច្បាប់អន្តរជាតិដែលប្រទេសជាសមាជិកត្រូវតែគោរពនិងអនុវត្តទៅតាមគោលការណ៍នៃច្បាប់ដែលបានអនុម័ត។ ជាក់ស្តែង នៅថ្ងៃទី០២ សីហា ១៩៩០ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ១៩៩១ ប្រទេសអ៊ីរ៉ាក់បានធ្វើសង្គ្រាមឈ្លានពានប្រទេសកូវ៉ែត ហើយ ពេលនោះ គេបានយកច្បាប់អន្តរជាតិទៅប្រើ ដោយអង្គការសហប្រជាជាតិបានចាត់កងកម្លាំងសន្តិ-សុខទៅបង្ក្រាបប្រទេសអ៊ីរ៉ាក់ដោយជោគជ័យ។ |
| **២៩- ឆ្វេងនិយម**<br>អ. leftism<br>បារ. gauchisme ( m. ) | និន្នាការឬមនោគមវិជ្ជានយោបាយដែលនិយមកំណែទម្រង់ជ្រុល និង និយមការធ្វើបដិវត្តន៍ដើម្បីផ្លាស់ប្តូរសណ្តាប់ធ្នាប់សង្គម ក្នុងគោល |

| | |
|---|---|
| | បំណាងពង្រីកសេរីភាពនិងសុខុមាលភាពសង្គមសម្រាប់ប្រជាជន ដោយប្រយុទ្ធតស៊ូប្រឆាំងនឹងវិសមភាពសង្គម ហើយ ប្រកាន់យកគោលការណ៍សមភាព។ នៅក្នុងវិស័យសេដ្ឋកិច្ច និន្នាការឆ្វេងនិយមប្រកាន់គោលការណ៍អន្តរាគមន៍របស់រដ្ឋតាមរយៈការដាក់បទបញ្ញានិងជាតូបនីយកម្មជាដើម។ គេអាចកំណត់ឆ្វេងនិយមបាន តាមរយៈការដឹកនាំសង្គម ការគ្រប់គ្រងរដ្ឋ សេដ្ឋកិច្ច និង នយោបាយ។<br>ឧទាហរណ៍ ៖<br>- មនោគមវិជ្ជាឆ្វេងនិយមមានឥទ្ធិពលក្រោយសង្គ្រាមលោកទី២។<br>- នៅសហរដ្ឋអាម៉េរិក មានគណបក្សបី គឺ League for Progressive Political Action, American Labor Party និង Black Panther Party ដែលប្រកាន់យកលទ្ធិឆ្វេងនិយម។ |
| **៣០- ជាតិនិយម**<br>អ. nationalism<br>បារ. nationalisme(m.) | ការលើកតម្កើងជាតិសាសន៍ខ្លួនឯងឱ្យដាច់គេ ការឱ្យតម្លៃទាបជាងខ្លួនដល់ជាតិសាសន៍ដទៃដែលជារដ្ឋឯករាជ្យដូចគ្នា។ លើសពីនេះទៀត ជាតិនិយមគឺជាការធ្វើឱ្យមានមនោសញ្ចេតនាចំពោះជាតិយ៉ាងពុះកញ្ជ្រោល ការស្រឡាញ់ជាតិរបស់ខ្លួននៅក្នុងមហិច្ឆតា ហើយ នៅពេលខ្លះ រហូតដល់ស្អប់និងរើសអើងជាតិសាសន៍ដទៃថែមទៀត។ |

| | |
|---|---|
| | ឧ. មុនសង្គ្រាមលោកលើកទី២ ជនជាតិអាល្លឺម៉ង់ជាជនជាតិដែលជាតិនិយមលើកតម្កើងជាតិសាសន៍ខ្លួនឯងជាងគេ ដែលជាបុព្វហេតុនាំឱ្យមានការប្រកាន់ពូជសាសន៍និងការបង្កើតសង្គ្រាម។ |
| **៣១- ជីកស្មៅជីកទាំងឫស**<br>អ. to get to the root of the problem<br>បារ. combattre le mal à la racine | ពាក្យប្រើប្រាស់ជាសាកលក្នុងរបបផ្ដាច់ការ។ ដោយឡែក ក្នុងសង្គមខ្មែរ ពាក្យនេះបានយកមកប្រើពេញនិយម និង អនុវត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)។ តាមន័យត្រង់ ដើម្បីកុំឱ្យស្មៅដុះសាជាថ្មី គេត្រូវជីកយកទាំងឫស។ តាមន័យនយោបាយ បើគេយល់ថាក្រុមណាឬបុគ្គលណាមួយដែលជាគូប្រជែងឬគូប្រឆាំងមិនពេញចិត្តទៅនឹងមនោគមវិជ្ជារបស់គេត្រូវគេកម្ទេចចោលទាំងអស់ ដើម្បីកុំឱ្យប្រឆាំងតបតមកវិញ។<br>ឧ. នៅឆ្នាំ១៩១៧ បដិវត្តន៍រុស្ស៊ីបានអនុវត្តនយោបាយ ជីកស្មៅជីកទាំងឫស ដោយបានសម្លាប់រាជវង្សស្ដេចត្សារទាំងពូជ។ |
| **៣២- ជំងឺតួឯក**<br>អ. egotism<br>បារ. égotisme ( m. ) | ទស្សនៈអាត្មានិយម បុគ្គលនិយមដែលប្រកាន់ថា មានតែខ្លួនទេដែលល្អជាច់គេ លើសគេ ផុតគេ ជាអ្នកសំខាន់ឬអស្ចារ្យជាងគេ ប្រសិនបើពុំមានវត្តមានរបស់ខ្លួនទេ ពុំមាននរណាផ្សេងអាចជំនួសខ្លួនបានឡើយ។ |

| | |
|---|---|
| **៣៣- ជំនួយស្មារតី**<br>អ. aide-memoire<br>បារ. aide mémoire (f.) | លិខិតដែលប្រគល់ឬផ្ញើជូន បន្ទាប់ពីមានកិច្ចសន្ទនាការទូតមួយ ដើម្បីជៀសវាងការយល់ច្រឡំគ្នាទាក់ទងនឹងសេចក្តីថ្លែងនៅពេលសន្ទនាជាមួយគ្នា។<br>ឧ. ជំនួយស្មារតីស្តីពីការផ្តល់គ្រូបង្ហាត់កីឡារបស់ប្រទេសជប៉ុនមកបង្ហាត់កីឡាករកម្ពុជា។ |
| **៣៤- តុល្យភាពអំណាច**<br>អ. balance of power<br>បារ. équilibre (f.)<br>de pouvoirs (m.) | ការបែងចែកអំណាចនៃរដ្ឋនិងរដ្ឋឬបក្សសម្ព័ន្ធនិងសម្ព័ន្ធមិត្តដែលប្រឆាំងគ្នា ហើយ ការបែងចែកនេះមិនមានរដ្ឋឬបក្សសម្ព័ន្ធណាមួយមានប្រៀបជាងរដ្ឋឬបក្សសម្ព័ន្ធណាមួយទេ។<br>ឧ. សហរដ្ឋអាម៉េរិកនិងសហភាពសូវៀតបានរក្សាឱ្យមានតុល្យភាពអំណាចក្នុងការប្រើប្រាស់ចំនួនអាវុធនុយក្លេអ៊ែរស្មើគ្នា នៅក្នុងទសវត្សរ៍៧០-៨០នៃសតវត្សរ៍ទី២០ ដែលបានជួយធ្វើឱ្យមាននិរន្តរភាពនៃតុល្យភាពអំណាចខាងយោធា។ |
| **៣៥- ទណ្ឌកម្មច្បាប់សង្គ្រាម**<br>អ. sanctions of war laws<br>បារ. sanctions (f.)<br>en application (f.)<br>des lois (f.)<br>de guerre (f.) | ជាវិធានការផ្លូវច្បាប់ស្តីពីការដាក់ទោសចំពោះអ្នកដឹកនាំរដ្ឋឬក្រុមមនុស្សណាមួយដែលមិនគោរពច្បាប់សង្គ្រាមអន្តរជាតិក្នុងការធ្វើសង្គ្រាម។ ច្បាប់អន្តរជាតិ ជារឿយៗ ត្រូវបានគេរិះគន់ដោយហេតុថា គ្មានការដាក់ទណ្ឌកម្ម។ ជាការពិតណាស់ បើប្រៀបធៀបទៅនឹងច្បាប់របស់រដ្ឋ ច្បាប់អន្តរជាតិមានការដាក់ទណ្ឌកម្មតិចតួចណាស់។ ច្បាប់សង្គ្រាម ជាញឹកញាប់ ត្រូវបាន |

| | |
|---|---|
| | គេរំលោភបំពាន ប៉ុន្តែ ច្បាប់អន្តរជាតិពុំមានមធ្យោបាយណាមួយ ដើម្បីបង្ខំឱ្យរដ្ឋទាំងអស់ប្រតិបត្តិតាមច្បាប់នេះឡើយ។ ជាទូទៅ នៅក្នុងករណីប្រទេសមហាអំណាចជាអ្នកបង្កសង្គ្រាម ប្រទេសនោះមិនត្រូវបានគេដាក់ទណ្ឌកម្មនោះទេ។ ផ្ទុយទៅវិញ ប្រទេសតូចតាចនិងទន់ខ្សោយតែងតែទទួលរងការដាក់ទណ្ឌកម្មសង្គ្រាម។<br>ឧ. លោក Slobodan Milosevic (១៩៤១-២០០៦) ដែលជាប្រធានាធិបតីសាធារណរដ្ឋសែប៊ី ពីឆ្នាំ១៩៨៩ដល់១៩៩៧ និង ជាប្រធានសហព័ន្ធសាធារណរដ្ឋយូហ្គោស្លាវី ពីឆ្នាំ១៩៩៧-២០០០ ត្រូវបានគេចោទប្រកាន់ជាឧក្រិដ្ឋជនសង្គ្រាម ហើយ ត្រូវបានគេកាត់ទោសតាមច្បាប់អន្តរជាតិស្ដីពីឧក្រិដ្ឋកម្មសង្គ្រាម។<br>ទណ្ឌកម្មសង្គ្រាមមានដូចតទៅ ៖<br>១-ការផ្ចាញ់តប (reprisal) : ជាវិធានការដ៏ចំណាស់មួយនៅក្នុងចំណោមវិធានការនានានៃច្បាប់អន្តរជាតិ។ ការផ្ចាញ់តប គឺជាមធ្យោបាយមួយដើម្បីបង្ខំឱ្យបណ្ដារដ្ឋដែលឈ្លោះគ្នាទាំងអស់ប្រតិបត្តិតាមវិធាននៃការធ្វើសង្គ្រាម។ ក្នុងពេលថ្មីៗនេះ ការផ្ចាញ់តប ជារឿយៗ ធ្វើឱ្យរដ្ឋាភិបាលមានជម្លោះប្រតិបត្តិតាមវិធាននៃច្បាប់ស្ដីពីសង្គ្រាម។ |

| | |
|---|---|
| | ២- ការដាក់ទណ្ឌកម្មលើឧក្រិដ្ឋជនសង្គ្រាម (punishment of war criminals): ជនណាដែលមានកំហុសពីបទឧក្រិដ្ឋសង្គ្រាមអាចត្រូវបានចាប់ខ្លួននិងកាត់ទោស។ ក្រោយសង្គ្រាមលោកលើកទី២ មានឧក្រិដ្ឋជនសង្គ្រាមមួយចំនួនត្រូវបានគេឃុំខ្លួន និង ជនដែលគេរកឃើញថាមានកំហុសពីបទឧក្រិដ្ឋកម្មសង្គ្រាម ត្រូវបានគេកាត់ទោស។ នៅក្នុងចំណោមសវនការស្តីពីបទឧក្រិដ្ឋកម្មសង្គ្រាម មានសវនការ នៅទីក្រុងនុយរ៉ុមប៊ែរ និង ទីក្រុងតូក្យូ។<br>៣- សំណង(compensation): រដ្ឋមានជម្លោះមួយដែលរំលោភបំពានលើច្បាប់នានាដែលទាក់ទងទៅនឹងសង្គ្រាមអាចត្រូវបានបង្ខំឱ្យបង់សំណងសម្រាប់ការរំលោភបំពាននោះ។<br>មាត្រា៣នៃអនុសញ្ញាទីក្រុងឡាអេ នាឆ្នាំ ១៩០៧ ចែងថា " រដ្ឋមួយដែលបានរំលោភច្បាប់សង្គ្រាមអាចត្រូវបានបង្ខំឱ្យបង់សំណងចំពោះការរំលោភបំពាននោះ"។ |
| **៣៦- ទឹកដីអាណានិគម**<br>អ. colony<br>បារ. colonie (f.) | ទឹកដីរបស់ប្រទេសមួយដែលមានអំណាចទន់ខ្សោយត្រូវបានគ្រប់គ្រងដោយរដ្ឋបរទេសមួយដែលមានអំណាចខ្លាំងជាង។<br>ឧ. នៅចុងសតវត្សរ៍ទី១៩ ប្រទេសកម្ពុជា វៀតណាម ឡាវ គឺជាទឹកដីអាណានិគមរបស់ប្រទេសបារាំង។ |

| | |
|---|---|
| **៣៧- ធម្មនុញ្ញ**<br>អ. charter<br>បារ. charte (f.) | ក្រមឬលិខិតូបករណ៍នានាដែលមានលក្ខណៈផ្លូវការក្នុងការបង្កើតអង្គការអន្តរជាតិណាមួយ ឬស្ថាប័នណាមួយ។<br>ឧ. ធម្មនុញ្ញអង្គការសហប្រជាជាតិ ធម្មនុញ្ញអាជ្ញាធរជាតិប្រឆាំងនឹងជំងឺអេដស៍ ធម្មនុញ្ញគណៈកម្មាធិការអូឡាំពិកអន្តរជាតិ។ |
| **៣៨- នយោបាយ**<br>អ. politics<br>បារ. politique (f.) | វិធីសាស្រ្ត សិល្បៈ បច្ចេកទេសក្នុងការដឹកនាំគ្រប់គ្រងរដ្ឋឬរដ្ឋាភិបាល។ តាមន័យនេះ យើងអាចសង្កេតឃើញថា ពាក្យ នយោបាយ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹង រដ្ឋ មានន័យថា នៅពេលមានព្រំសីមាឬបុរី នៅពេលនោះការគ្រប់គ្រងនយោបាយ គឺជាកិច្ចការដែលទាក់ទងទៅនឹងមនុស្សនៅក្នុងរដ្ឋឬបុរី។<br>ឧ. នៅដើមសតវត្សទី១នៃគ្រិស្តសករាជ ប្រទេសកម្ពុជាបានបង្កើតទៅជារដ្ឋ ដោយមានការគ្រប់គ្រងតាមបែបនយោបាយដែលមានក្សត្រី លីវយី ជាប្រមុខដឹកនាំ។ |
| **៣៩- នយោបាយ កលិយុគ**<br>អ. chaotic politics<br>បារ. politique chaotique (f.) | ស្ថានភាពវឹកវរទាំងឡាយដែលបង្កើតឡើងដោយអ្នកដឹកនាំឬអ្នកនយោបាយ ក្នុងសម័យកាលណាមួយ ក្នុងគោលបំណងដណ្តើមយកអំណាច ឬដោះដូរអំណាច តាមរយៈមហាជន និង តាមមធ្យោបាយផ្សេងៗទៀត។ |

| | |
|---|---|
| | ឧ. នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៣ សហរដ្ឋអាម៉េរិកបានធ្វើសង្គ្រាមបណ្ដេញលោក សាដាំ ហូសេន ប្រធានាធិបតីប្រទេសអ៊ីរ៉ាក់ ចេញពីអំណាច ដោយចោទប្រកាន់ថាបានផលិតអាវុធនុយក្លេអ៊ែរអាវុធគីមីនិងដឹកនាំប្រទេសផ្ដាច់ការ។ ផ្ទុយទៅវិញ តាមរយៈរបាយការណ៍អង្កេតជាក់ស្ដែងរបស់ភ្នាក់ងារជំនាញអង្គការសហប្រជា-ជាតិ គេពុំបានរកឃើញភស្តុតាងណាមួយបញ្ជាក់ថា ប្រទេសអ៊ីរ៉ាក់បានផលិតអាវុធ ដូចការចោទប្រកាន់នោះទេ។ |
| **៤០- នយោបាយការ៉ុត និងដំបង**<br>អ. carrot and stick policy<br>បារ. politique ( f. ) de la carotte et du bâton | នយោបាយប្រើប្រាស់ការទូតផងនិងកម្លាំងផងក្នុងពេលតែមួយ តាមគ្រប់រូបភាពដែលអាចធ្វើទៅបាន រួមមាន ការចរចា ការផ្ដល់ជំនួយ ការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ការផ្ដាច់ទំនាក់ទំនងការទូត និង ការប្រើកម្លាំងយោធា ជាដើម។<br>ឧ. នយោបាយការ៉ុត និង ដំបងរបស់អង្គការសហប្រជាជាតិចំពោះប្រទេសអ៊ីរ៉ង់អំពីបញ្ហាអាវុធនុយក្លេអ៊ែរ។ |
| **៤១- នយោបាយច័ក្កច័ន** | ប្រភេទនយោបាយមួយ ដែលគេរៀបចំឡើងដោយមានពហុមនោគមវិជ្ជាដើម្បីសម្រេចគោលដៅណាមួយរបស់អ្នកនយោបាយ ដូចជា ការបង្កើតរដ្ឋាភិបាលឬចលនានយោបាយចម្រុះពណ៌។<br>ឧ. ក្រោយពីការដួលរលំរបបកម្ពុជាប្រជាធិប- |

| | |
|---|---|
| | តេយ្យឆ្នាំ១៩៧៩ ក្រុមអ្នកតស៊ូត្រីភាគីដែលមាននិន្នាការនយោបាយច័ក្កច័នបានរួបរួមគ្នាប្រឆាំងនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ |
| **៤២- នយោបាយចម្រុះពណ៌**<br>អ. multi-colored politics<br>បារ. politique multicolore ( f. ) | នយោបាយដែលទទួលយកមនោគមវិជ្ជានយោបាយគ្រប់និន្នាការ ក្នុងទិសដៅបង្ហាញពិភពលោកថា ខ្លួនមិនរើសអើងនិន្នាការនយោបាយ។<br>ឧ. ក្រោយពីការបង្កើតបក្សសម្ព័ន្ធសេអាតូ នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៥៤ ប្រទេសកម្ពុជាបានប្រកាសជាប្រទេសអព្យាក្រឹត មិនចូលបក្សសម្ព័ន្ធ។ ក្រោមនយោបាយនេះ ប្រទេសកម្ពុជាបានប្រើប្រាស់នយោបាយចម្រុះពណ៌ដើម្បីអាចទទួលបានជំនួយពីចិន រុស្ស៊ី អាម៉េរិក។ |
| **៤៣- នយោបាយទន់ភ្លន់**<br>អ. flexible politics<br>បារ. politique flexible ( f. ) | នយោបាយការទូតដែលប្រើប្រាស់ក្នុងការធ្វើទំនាក់ទំនងដែលមានលក្ខណៈប្រុងប្រយ័ត្នដោយធ្វើការសិក្សាស៊ីជម្រៅទៅលើអរិយធម៌របស់ប្រទេស ក្រុម ឬ បុគ្គលនោះ ជាមុនសិនមុននឹងធ្វើទំនាក់ទំនងទៅលើបញ្ហាណាមួយ។ នយោបាយទន់ភ្លន់នេះក៏គេអាចប្រើប្រាស់សម្រាប់ធ្វើការដោះស្រាយនយោបាយផ្ទៃក្នុងផងដែរ។<br>ឧទាហរណ៍ ៖<br>- ការដោះស្រាយជម្លោះបញ្ហានៅមជ្ឈិមបូព៌ា |

| | |
|---|---|
| | សហរដ្ឋអាម៉េរិកបានប្រើប្រាស់នយោបាយ ទន់ភ្លន់ ដើម្បីសិក្សាទៅលើទំនៀមទម្លាប់ ប្រពៃណីរបស់មជ្ឈិមបូព៌ា ដោយមិនប្រើ ច្បាប់អន្តរជាតិ ឬ ការទូតទាំងស្រុងទេ។<br>- ការជាប់គាំងនយោបាយក្រោយពីការបោះ ឆ្នោតឆ្នាំ២០០៣អស់រយៈពេល១ឆ្នាំមក សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បាន ប្រើប្រាស់នយោបាយទន់ភ្លន់ ដើម្បីចូល ចរចាជាមួយដៃគូហ៊្វុនស៊ិនប៉ិច។ |
| **៤៤- នយោបាយបង្កក**<br>អ. frozen politics<br>បារ. gel politique (m.) | នយោបាយដែលផ្តាច់ទំនាក់ទំនងជាមួយប្រទេស ណាមួយ ឬ ក្រុមណាមួយ ដែលបានប៉ះពាល់ ផលប្រយោជន៍ដល់ប្រទេសឬក្រុមនោះ។ នយោបាយបង្កកគឺមានន័យថា បញ្ឈប់ទំនាក់ ទំនងការបរទេស ការទូត និង ផ្នែកសេដ្ឋកិច្ច។ នយោបាយនេះកើតឡើងតែនៅក្នុងរយៈពេល ណាមួយដែលភាគីទាំងសងខាងមិនទាន់ឯក- ភាពឬស្រុះស្រួលគ្នា។<br>ឧ. នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ ក្រោយ ពីមានទំនាស់រវាងសហព័ន្ធរុស្ស៊ី និង ហ្សកហ្ស៊ី (Georgia)បានធ្វើឱ្យសហគមន៍អឺរ៉ុបនិងសហ- រដ្ឋអាមេរិកបង្កកទំនាក់ទំនងជាមួយរុស្ស៊ី។ ឯ រុស្ស៊ីវិញបានឆ្លើយតបនឹងសហគមន៍អឺរ៉ុបដោយ ធ្វើនយោបាយបង្កកវិញ តាមរយៈការផ្តាច់ការ |

| | |
|---|---|
| | ផ្គត់ផ្គង់ថាមពលឧស្ម័ន ដោយចោទអ៊ុយក្រែនថា បានប្លន់យកឧស្ម័នប្រាសចាកពីកិច្ចព្រមព្រៀងដែលធ្វើឱ្យទំនាស់នេះកាន់តែមានសភាពប្រឈមដាក់គ្នាកាន់តែតានតឹងឡើងរវាងរុស្ស៊ីនិងអឺរ៉ុបរហូតដល់ថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៩ ទើបមានជំនួបទ្វេភាគីរវាងនាយករដ្ឋមន្ត្រីអ៊ុយក្រែននិងនាយករដ្ឋមន្ត្រីសហព័ន្ធរុស្ស៊ី ដើម្បីធ្វើការដោះស្រាយបញ្ហានេះ ដោយមានការចូលរួមពីប្រទេសបារាំង អ៊ីតាលី អេស្ប៉ាញ អាល្លឺម៉ង់ផង។ |
| **៤៥-នយោបាយអត្តឃាត**<br>អ. suicidal politics<br>បារ. politique suicidaire ( f. ) | បុគ្គលឬក្រុមបក្សនយោបាយណាមួយ ដែលគេបង្កើតឡើងគ្មានមូលដ្ឋានរឹងមាំ ហើយ ត្រូវទទួលបរាជ័យនិងបាត់ឈ្មោះពីក្នុងបញ្ជីគណបក្សនយោបាយទៅវិញក្រោយពីមានការប្រកួតប្រជែង។ |
| **៤៦- បទដ្ឋានសង្គ្រាម**<br>អ. rule of war<br>បារ. droit ( m. ) de la guerre | វិធានទាំងឡាយណាដែលមានចែងនៅក្នុងច្បាប់អន្តរជាតិនិងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធនឹងសង្គ្រាម។ សិទ្ធិកាតព្វកិច្ចដែលភាគីពាក់ព័ន្ធនៅក្នុងសង្គ្រាមត្រូវគោរពពេលធ្វើសង្គ្រាមមានដូចខាងក្រោម ៖<br>១. អំឡុងពេលមានសង្គ្រាម ការសម្លាប់ជនស៊ីវិលគ្មានអាវុធដោយចេតនា មិនត្រូវបានអនុញ្ញាតឡើយ។<br>២. ទាហានម្ខាងមិនអាចសម្លាប់ឬធ្វើឱ្យរបួសដល់ទាហានម្ខាងទៀត ដែលបាន |

| | |
|---|---|
| | ចុះចូលហើយនោះទេ។<br>៣. មន្ទីរពេទ្យមិនត្រូវបានប៉ះពាល់ឬវាយប្រហារទេ ក្នុងពេលមានសង្គ្រាម។<br>៤. ឈ្លើយសឹកមិនត្រូវបានគេប្រព្រឹត្តដោយអមនុស្សធម៌ឬធ្វើទារុណកម្មទេ។<br>៥. ការចាប់យកឬសម្លាប់ចំណាប់ខ្មាំងមិនត្រូវអនុញ្ញាតឡើយ។<br>៦. ទាហានត្រូវពាក់ឯកសណ្ឋានដើម្បីឱ្យគេបានស្គាល់អត្តសញ្ញាណច្បាស់លាស់ ជៀសវាងការច្រឡំជាមួយជនស៊ីវិល។<br>៧. សមរភូមិត្រូវធ្វើឱ្យឆ្ងាយពីតំបន់ទីក្រុងដែលមានប្រជាជនរស់នៅ។<br>៨. នៅពេលត្រូវវាយប្រហារទៅលើទីក្រុង ត្រូវទុកពេលវេលាសម្រាប់ជម្លៀសជនស៊ីវិលចេញ។<br>៩. ជនស៊ីវិលស្លូតត្រង់ត្រូវទទួលការគាំពារ។ |
| **៤៧- បទល្មើសសង្គ្រាម**<br>អ. war crime<br>បារ. crime ( m. ) de guerre ( f. ) | ការរំលោភខាងយោធាទៅលើបទដ្ឋាននៃការធ្វើសង្គ្រាម រួមមាន សកម្មភាពឃោរឃៅ ការធ្វើទុក្ខបុកម្នេញ នៅក្នុងពេលធ្វើសង្គ្រាម។ បទល្មើសសង្គ្រាមរួមមាន ៖<br>១. ការប្រើប្រាស់អាវុធដែលហាមឃាត់<br>២. ការមិនយកចិត្តទុកដាក់ដល់អ្នកជំងឺ ឬអ្នករបួស<br>៣- ការរំលោភបំពានរថយន្តដែលមានទង់ |

| | |
|---|---|
| | ឬ សញ្ញាកាកបាទក្រហម<br>៤-ការបំពានដោយមិនដោះលែងអ្នកទោស ឬ ដោយបទឈប់បាញ់គ្នា<br>៥- ការសម្លាប់ចំណាប់ខ្មាំង<br>៦- ការសម្លាប់រង្គាលជនមិនមែនស៊ីវិល ឬ បច្ចាមិត្ត ដែលបានចុះចូល<br>៧- ការបំផ្លាញនាវាចម្បាំងដោយមិនបានយកអ្នកដំណើរ ឬ បុគ្គលិកនាវាទៅដាក់កន្លែងមានសុវត្ថិភាព<br>៨- ការទម្លាក់គ្រាប់បែកលើទីកន្លែងដែលគ្មានរបាំងការពារអ្វីទាំងអស់ ឬ អគារនានាដែលមិនមែនជាគោលដៅខាងយោធា។ |
| **៤៨- បាតុកម្ម**<br>អ. demonstration<br>បា. manifestation ( f. ) | អំពើដាក់ស្តែង ការធ្វើឱ្យដឹងឬឱ្យឃើញប្រាកដ ការលើកគ្នាដើរដង្ហែជាក្បួនដើម្បីសម្តែងសេចក្តីមិនពេញចិត្តចំពោះអំពើអ្វីមួយឬទទូចសុំស្រុះគ្នាឱ្យសម្រេចផលប្រយោជន៍អ្វីមួយតាមសេចក្តីពេញចិត្តរបស់ក្រុមខ្លួន។ |
| **៤៩- បុព្វសិទ្ធិការទូត**<br>អ. diplomatic privileges<br>បារ. privilèges diplomatiqes ( m. ) | សិទ្ធិទាំងឡាយដែលរដ្ឋម្ចាស់ផ្ទះផ្តល់ជូនសកម្មភាពការងាររបស់បេសកកម្មការទូតទាំងនោះ ដើម្បីដោះស្រាយបំបាត់ភាពសាំញ៉ាំរដ្ឋបាលទូទៅនៅក្នុងរដ្ឋម្ចាស់ផ្ទះ ដូចជា ការលើកលែងការបង់ពន្ធដីរបស់ស្ថានទូត ពន្ធលើបៀរត្សរ៍របស់បុគ្គលិកស្ថានទូត ការនាំចូលសម្ភារៈ និងយានជំនិះសម្រាប់ស្ថានបេសកកម្មនិងបុគ្គលិក |

| | |
|---|---|
| | ផ្ទាល់ខ្លួន ដោយការបង់ពន្ធជាបន្ទុករបស់រដ្ឋម្ចាស់ផ្ទះ។ |
| **៥០- បេសកកម្មការទូត**<br>អ. diplomatic mission<br>បារ. mission diplomatique ( f. ) | ស្ថានតំណាងផ្លូវការរបស់ប្រទេសមួយប្រចាំនៅជានីនៃប្រទេសមួយទៀត ហើយ បេសកកម្មនេះអាចបង្កើតឡើងបាន លុះត្រាតែមានការព្រមព្រៀងគ្នាជាមុនរវាងប្រទេសទាំងពីរ។<br>ឧ. នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៩៦ ព្រះរាជាណាចក្រកម្ពុជាបានព្រមព្រៀងជាមួយសាធារណរដ្ឋកូរ៉េ( កូរ៉េខាងត្បូង )ដើម្បីស្ថាបនាឡើងវិញនូវបេសកកម្មការទូត ដែលបានអាក់ខានអស់រយៈពេលជាង២០ឆ្នាំមកហើយ។ |
| **៥១- ប្រជាជាតិ**<br>អ. nation<br>បា. nation ( f. ) | ក្រុមមនុស្សដែលរស់នៅលើទឹកដីមួយស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលមួយ មានសញ្ជាតិនិងភាសាផ្លូវការតែមួយ មានវប្បធម៌ ដូចគ្នាឬផ្សេងៗគ្នា ទំនៀមទម្លាប់ប្រហាក់ប្រហែលគ្នាមានប្រវត្តិសាស្ត្រទាក់ទងរវាងជាតិសាសន៍ដែលរស់នៅជាមួយគ្នា។<br>ឧ. មុនខែមិថុនា ឆ្នាំ១៩៩១ អតីតប្រទេសយូហ្គោស្លាវីជារដ្ឋសហព័ន្ធដែលមានប្រជាជាតិ៦ជាផ្លូវការ រួមមាន ស៊ែប៊ី ក្រូអាត អាល់បានីស្លូវេនី ម៉ាសេដ្វាន និង ម៉ុងតេណេក្រូ ។ |
| **៥២- ផ្តាច់ការ**<br>អ. absolute | - បញ្ញត្តិដែលស្តែងពីបុគ្គលដែលធ្វើឡើងដោយមិនចំណុះទៅលើអ្វីមួយ។ |

| | |
|---|---|
| បារ. absolu ( m. ) | - បញ្ញត្តិដែលស្ដែងពីការគ្មានការបែងចែកអំណាច។ |
| **៥៣- ផ្ដាច់ការនិយម**<br>អ.  absolutism<br>បារ. absolutisme ( m. ) | ទម្រង់ដឹកនាំរដ្ឋដែលអំណាចដឹកនាំស្ថិតនៅក្នុងកណ្ដាប់ដៃមនុស្សម្នាក់នូវអំណាចទាំងបី គឺ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ។<br>ឧ. របបរាជានិយមផ្ដាច់ការ។ |
| **៥៤- ពិធីសារ**<br>អ.  protocol<br>បារ. protocole ( m. ) | ឯកសារដែលមានតម្លៃស្មើកិច្ចព្រមព្រៀង តែពិធីសារនេះមានលក្ខណៈផ្លូវការតិចជាងកិច្ច-ព្រមព្រៀង។<br>ពិធីសារមានឋានានុក្រមដូចតទៅ៖<br>- ពិធីសារចុះហត្ថលេខា គឺជាឯកសារបន្ទាប់បន្សំរបស់សន្ធិសញ្ញា។ ពិធីសារនេះសម្រាប់ដោះស្រាយបញ្ហាបន្ទាប់បន្សំនានា ដូចជា ការបកស្រាយខពិសេសនានារបស់សន្ធិសញ្ញា ដោយខទាំងនេះមិនមានបញ្ចូលក្នុងសន្ធិសញ្ញា ឬបទបញ្ញត្តិនៃបញ្ហាបច្ចេកទេស ជាដើម,<br>ឧ. ពិធីសារស្ដីពីឋានៈរបស់ជនភៀសខ្លួន ឆ្នាំ ១៩៦៦។<br>- ពិធីសារជម្រើសជាឯកសារដែលត្រូវបាន អនុម័តក្នុងថ្ងៃតែមួយជាមួយនឹងសន្ធិសញ្ញា។ ពិធីសារនេះផ្ដល់ឱ្យភាគីទាំងឡាយដែលបាន ចុះសន្ធិសញ្ញាជាមួយគ្នា បង្កើតនូវលទ្ធភាព |

| | |
|---|---|
| | របនាសម្ព័ន្ធនៃកាតព្វកិច្ចរវាងគ្នា បន្ថែមលើកាតព្វកិច្ចដែលមានក្នុងសន្ធិសញ្ញា,<br>ឧ. ពិធីសារ នាឆ្នាំ១៩៥៣ ស្តីពីការកែប្រែអនុសញ្ញាទាសភាព ឆ្នាំ១៩២៦។<br>- ពិធីសារធ្វើវិសោធនកម្ម គឺជាឯកសារមួយដែលចែងអំពីបទបញ្ញត្តិទាក់ទងនឹងវិសោធនកម្មលើចំណុចណាមួយ ឬ ចំណុចមួយចំនួននៃសន្ធិសញ្ញាដើម,<br>ឧ. ពិធីសារជម្រើសនៃទីក្រុងវីយែនឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូតដែលផ្តោតទៅលើការដោះស្រាយជម្លោះដោយបង្ខំ។ |
| **៥៥- ពិភពលោកមួយ ភូមិមួយ**<br>អ. one world one village<br>បារ. un monde un village | ពាក្យពេញនិយម ដែលគេប្រើប្រាស់ក្នុងសម័យសាកលភាវូបនីយកម្មសំដៅទៅលើទំនាក់ទំនងរបស់មនុស្សកាន់តែមានភាពងាយស្រួល និងឆាប់រហ័ស ឯឥទ្ធិពលនិងផលប៉ះពាល់ ក៏មានភាពរាលដាលយ៉ាងឆាប់រហ័សពាសពេញពិភពលោកដែរ ក្នុងវិស័យទាំងឡាយ ដូចជា នយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន ព័ត៌មាន បច្ចេកវិទ្យា ការអប់រំ ជាដើម។<br>ឧ. វិបត្តិសេដ្ឋកិច្ចនៅចុងឆ្នាំ២០០៨ បានធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចទូទាំងពិភពលោក។ |

| | |
|---|---|
| **៥៦- ភារធារី**<br>អ. chargé d'affaires<br>បារ. chargé ( m. )<br>d'affaires ( f. ) | ១- ប្រមុខបេសកកម្មការទូតថ្នាក់ទី៣ នៅជាអចិន្ត្រៃយ៍អមក្រសួងការបរទេស។<br>២- សមាជិកបេសកកម្មការទូតទទួលបន្ទុកទទួលខុសត្រូវជាប្រមុខបេសកកម្មការទូតស្តីទីក្នុងករណីអវត្តមានរបស់ប្រមុខបេសកកម្មការទូត។<br>៣- តាមក្រមរដ្ឋប្រវេណីមានន័យថា មន្ត្រីការទូតដែលទទួលភារកិច្ចជាមន្ត្រីអគ្រានុកូលដ្ឋានប្រចាំស្ថានទូត។<br>មន្ត្រីការទូតជាន់ខ្ពស់ដែលមានឋានៈបន្ទាប់ពីឯកអគ្គរដ្ឋទូត ហើយ ទទួលភារកិច្ចជាប្រធានបេសកកម្មការទូត ដោយជំនួសឯកអគ្គរដ្ឋទូតនៅពេល ដែលឯកអគ្គរដ្ឋទូតអវត្តមាន។<br>ឧ. លោក R. Eko Indiarto R ត្រូវបានតែងតាំងឱ្យមកធ្វើជាប្រធានបេសកកម្មការទូតឥណ្ឌូណេស៊ីបណ្ដោះអាសន្នប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានឋានៈជាភារធារី បន្ទាប់ពីឯកឧត្តម Nurrachman Oerip អតីតឯកអគ្គរដ្ឋទូតសាធារណរដ្ឋឥណ្ឌូណេស៊ីប្រចាំប្រទេសកម្ពុជាបានបញ្ចប់បេសកកម្មការទូតរបស់ខ្លួន។ |
| **៥៧- មូលធននិយម**<br>អ. capitalism<br>បារ. capitalisme ( m. ) | ប្រព័ន្ធនយោបាយនិងសេដ្ឋកិច្ចដែលតាមរយៈនោះ ឯកជនរៀបចំនិងគ្រប់គ្រងវិស័យពាណិជ្ជកម្ម និងឧស្សាហកម្ម។ |

| | |
|---|---|
| **៥៨- យុទ្ធសាស្ត្រដុតឱ្យខ្លោចរោចឱ្យឆៅ** | យុទ្ធសាស្ត្ររបស់អ្នកនយោបាយ ដែលរុញឬបង្អាក់បញ្ហាណាមួយឱ្យបរាជ័យហើយ បង្ហាញបញ្ហានោះឱ្យសាធារណជនមើលឃើញ ដើម្បីឆក់យកអំណាចឬយកប្រៀបខាងនយោបាយ។ ម្យ៉ាងវិញទៀត ដើម្បីចាប់កំហុសឬទម្លាក់នរណាម្នាក់ចេញពីតំណែង គេក៏ប្រើវិធីនេះផងដែរ។ |
| **៥៩- យុទ្ធសាស្ត្រព្រួញមួយ បាញ់បានសត្វពីរ**<br>អ. kill two birds with one stone<br>បារ. faire d' une pièrre deux coups ( m. ) | ភាពប៉ិនប្រសប់របស់អ្នកនយោបាយក្នុងការដោះស្រាយបញ្ហាអ្វីមួយ ដោយប្រើមធ្យោបាយតែមួយ ហើយ អាចដោះស្រាយបញ្ហាពីរឬច្រើន ឬ ផ្ដល់គុប្រយោជន៍ពីរឬច្រើនបាន។ |
| **៦០- រដ្ឋធម្មនុញ្ញ**<br>អ. constitution<br>បារ. constitution ( f. ) | ច្បាប់កំពូលរបស់រដ្ឋដែលត្រូវបានប្រើជាមូលដ្ឋានសម្រាប់បង្កើតច្បាប់ផ្សេងៗ ដើម្បីគ្រប់គ្រងរដ្ឋ។ ច្បាប់នេះកំណត់អំពីគោលការណ៍រួមនៃការបែងចែកអំណាចនៅក្នុងការគ្រប់គ្រងរដ្ឋ ដំណើរប្រព្រឹត្តទៅនៃស្ថាប័នកំពូលរបស់រដ្ឋ និង សិទ្ធិ និងការទទួលខុសត្រូវជាមូលដ្ឋានរបស់ពលរដ្ឋគ្រប់រូប។<br>ឧ. រដ្ឋធម្មនុញ្ញដំបូងនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រកាសឱ្យប្រើជាផ្លូវការដោយព្រះបាទនរោត្តមសីហនុនៅឆ្នាំ១៩៤៧ បន្ទាប់ពីសភាជាតិបានអនុម័តរួចមក។ |

| | |
|---|---|
| **៦១- រដ្ឋាភិបាល**<br>អ. government<br>បារ. gouvernement<br>(m.) | អង្គការចាត់តាំងរបស់ប្រជាជននៅក្នុងរដ្ឋមួយដែលមានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់និងគ្រប់គ្រងកិច្ចការនានារបស់រដ្ឋ។ រដ្ឋាភិបាលគឺជាផ្នែកមួយរបស់រដ្ឋគ្មានលក្ខណៈអចិន្ត្រៃយ៍ និងអាចមានការផ្លាស់ប្តូរតាមរយៈបដិវត្តន៍ រដ្ឋប្រហារ ការបោះឆ្នោត និង វិធីផ្សេងៗខាងផ្លូវច្បាប់។<br>ឧ. ចលនាតស៊ូរបស់ខ្មែរក្រហមផ្តួលរំលំរដ្ឋាភិបាលសាធារណរដ្ឋខ្មែរប្រកបដោយជោគជ័យនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ |
| **៦២- រដ្ឋាភិបាលផ្តាច់ការ**<br>អ. absolute government<br>បារ. gouvernement absolu (m.) | រដ្ឋាភិបាលដែលដឹកនាំដោយមនុស្សម្នាក់ឬមនុស្សមួយក្រុម ហើយ គ្រប់ដណ្តប់លើអំណាចទាំងបី គឺ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ។<br>រដ្ឋាភិបាលប្រភេទនេះមិនអនុញ្ញាតឱ្យប្រជាជនមានសិទ្ធិបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និង មានសិទ្ធិបញ្ចេញមតិក្នុងកិច្ចការរដ្ឋឡើយ។<br>ឧ. ប្រព័ន្ធដឹកនាំរដ្ឋបែបរាជានិយមផ្តាច់ការនិងកុម្មុយនីស្តនិយម តែងតែដឹកនាំរដ្ឋដោយរដ្ឋាភិបាលផ្តាច់ការ។ |
| **៦៣- លិខិតឆ្លងដែន**<br>អ. passport<br>បារ. passeport (m.) | ឯកសារផ្លូវការដែលបញ្ជាក់អំពីអត្តសញ្ញាណនិងសញ្ជាតិរបស់ពលរដ្ឋ ដែលអាជ្ញាធរមានសមត្ថកិច្ចផ្តល់ឱ្យសម្រាប់ធ្វើដំណើរទៅបរទេស ក្រោមការគាំពាររបស់រដ្ឋាភិបាលសាមី។ |

| | |
|---|---|
| **៦៤- លិខិតឆ្លងដែន ការទូត**<br>**អ.** diplomatic passport<br>**បារ.** passeport diplomatique (m.) | លិខិតឆ្លងដែនដែលអាជ្ញាធរមានសមត្ថកិច្ចផ្តល់ឱ្យមន្ត្រីការទូតនិងឥស្សរជនជាន់ខ្ពស់ សម្រាប់បំពេញបេសកកម្មនៅបរទេសតាមការកំណត់របស់រដ្ឋនីមួយៗ។<br>ឧ. យោងអនុក្រឹត្យលេខ២០២ អនក្រ-បក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៨របស់រាជរដ្ឋាភិបាលកម្ពុជា លិខិតឆ្លងដែនការទូតចេញថ្វាយនិងជូនដល់ឥស្សរជនជាន់ខ្ពស់និងមន្ត្រីការទូតខ្មែរ ទៅតាមលំដាប់នៃឋានន្តរសក្តិនិងមុខតំណែង ព្រមទាំងសហព័ទ្ធនិងកូន ដែលនៅក្នុងបន្ទុកនៅលីវ ហើយ មានអាយុក្រោម១៨ឆ្នាំ ដូចខាងក្រោម៖<br>១- ព្រះមហាវីរក្សត្រ ព្រះវររាជមាតា ព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី ឬ សម្តេចព្រះរាជអគ្គមហេសី។<br>២- ព្រះរាជបុត្រា ព្រះរាជបុត្រី ព្រមទាំងព្រះរាជវង្សានុវង្ស ដែលបញ្ជាក់ដោយក្រសួងព្រះបរមរាជវាំង។<br>៣- ប្រធាន អនុប្រធាន និង សមាជិកព្រឹទ្ធសភា ប្រធាន អនុប្រធាននិងសមាជិករដ្ឋសភា។<br>៤- ប្រធាន និង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។<br>៥- នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ព្រមទាំងរដ្ឋលេខាធិការ(ដែលជាប្រធានស្ថាប័នរបស់រាជរដ្ឋាភិបាល) |

| | |
|---|---|
| | ទេសាភិបាលធនាគារជាតិនៃកម្ពុជានិង អគ្គលេខាធិការរាជរដ្ឋាភិបាល។<br>៦- ប្រធានតុលាការកំពូល អគ្គព្រះរាជ អាជ្ញាអមតុលាការកំពូល។<br>៧- អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ និង អគ្គស្នងការនគរបាលជាតិ។<br>៨- ឧត្តមប្រឹក្សាផ្ទាល់របស់ព្រះមហាក្សត្រ និង ឥស្សរជនដែលមានងារជាសម្តេច។<br>៩- អតីតប្រធានព្រឹទ្ធសភា អតីតប្រធានរដ្ឋសភា អតីតនាយករដ្ឋមន្ត្រី អតីតឧបនាយករដ្ឋមន្ត្រីនិងអតីតរដ្ឋមន្ត្រីក្រសួងការបរទេស។<br>១០- នាយកខុទ្ទកាល័យព្រះមហាក្សត្រ នាយកខុទ្ទកាល័យប្រធានព្រឹទ្ធសភា នាយកខុទ្ទ-កាល័យប្រធានរដ្ឋសភា នាយកខុទ្ទកាល័យនាយករដ្ឋមន្ត្រី ដែលតែងតាំងដោយព្រះរាជក្រឹត្យ។<br>១១- ប្រធានពិធីការរបស់ព្រះមហាក្សត្រ ប្រធានពិធីការរបស់ប្រធានព្រឹទ្ធសភា ប្រធានពិធី-ការរបស់រដ្ឋសភា និង ប្រធានពិធីការរបស់នាយករដ្ឋមន្ត្រី។<br>១២- មន្ត្រីការទូតចាប់ពីអនុព័ន្ធឡើងទៅ ដែលត្រូវទៅធ្វើការនៅស្ថានទូត និង កុងស៊ុលនៅបរទេស។ |

| | |
|---|---|
| | ១៣- លិខិតឆ្លងដែនការទូតចេញថ្វាយ និង ប្រគេនសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ ទាំងពីរគណៈ និង មន្ត្រីសង្ឃដែលមានងារជាសម្តេច។ |
| **៦៥- លិខិតឆ្លងដែន ធម្មតា**<br>អ. normal passport<br>បារ. passeport normal ( m. ) | លិខិតឆ្លងដែនដែលអាជ្ញាធរមានសមត្ថកិច្ចផ្តល់ឱ្យពលរដ្ឋខ្មែរទាំងពីរភេទ សម្រាប់ធ្វើដំណើរទៅបរទេស តាមការកំណត់របស់រដ្ឋនីមួយៗ។<br>ឧ. យោងតាមអនុក្រឹត្យលេខ៦៨ អនក្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៤ នៅព្រះរាជាណាចក្រកម្ពុជា លិខិតឆ្លងដែនធម្មតាសម្រាប់ផ្តល់ជូនពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅសម្រាប់ធ្វើដំណើរទៅបរទេស។ កុមារអាយុតិចជាង១៨ឆ្នាំអាចស្នើសុំលិខិតឆ្លងដែននេះផ្ទាល់ខ្លួនបាន បើមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីឪពុកម្តាយ ឬ អាណាព្យាបាលដោយមានភ្ជាប់បណ្ណសម្គាល់គ្រួសារឬសំបុត្រកំណើតភ្ជាប់មកជាមួយពាក្យសុំលិខិតឆ្លងដែនរបស់សាមីខ្លួន។<br>ក្នុងករណីមានអាយុតិចជាង១២ឆ្នាំ ហើយ ធ្វើដំណើររួមជាមួយឪពុកម្តាយ ឬ អាណាព្យាបាល កុមារទាំងនោះត្រូវចុះក្នុងលិខិតឆ្លងដែន ឬ ឯកសារធ្វើដំណើររបស់ឪពុកម្តាយឬអាណាព្យាបាល។ |

| | |
|---|---|
| **៦៦- លិខិតឆ្លងដែន ផ្លូវការ**<br>អ. service passport<br>បារ. passeport (m.) de service (m.) | លិខិតឆ្លងដែនដែលអាជ្ញាធរមានសមត្ថកិច្ចផ្តល់ឱ្យមន្ត្រីរាជការទូទៅសម្រាប់បំពេញបេសកកម្មជាផ្លូវការនៅបរទេសតាមការកំណត់របស់រដ្ឋនីមួយៗ។<br>ឱ. យោងតាមអនុក្រឹត្យ លេខ៦៨ អនក្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៤ នៅព្រះរាជាណាចក្រកម្ពុជា លិខិតឆ្លងដែនផ្លូវការផ្តល់ជូនមន្ត្រីរាជការខ្មែរសម្រាប់តែទៅបំពេញបេសកកម្មផ្លូវការនៅក្រៅប្រទេសប៉ុណ្ណោះ៖<br>១- សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។<br>២- ទីប្រឹក្សា ឬ ជំនួយការមានឋានៈស្មើប្រធាននាយកដ្ឋានដល់អនុរដ្ឋលេខាធិការ។<br>៣- អនុប្រធានសាលាឧទ្ធរណ៍អគ្គព្រះរាជអាជ្ញារងសាលាឧទ្ធរណ៍ ចៅក្រម ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារង។<br>៤- អនុប្រធានអាជ្ញាធរជាតិ អនុប្រធាន គណៈ-កម្មាធិការជាតិ អនុប្រធាន ក្រុមប្រឹក្សាជាតិ និង អនុប្រធានស្ថាប័នថ្នាក់ជាតិនានា។<br>៥- ប្រធានសហគ្រាសសាធារណៈ និង គ្រឹះស្ថានសាធារណៈរបស់រដ្ឋ។<br>៦- មន្ត្រីដែលមានមុខតំណែងចាប់ពីអនុប្រធានការិយាល័យឡើងទៅ។ |

| | |
|---|---|
| | ៧- មន្ត្រីយោធានិងនគរបាលឋានៈចាប់ពីវរ-<br>សេនីយ៍ត្រីឡើងទៅ។<br>៨- បុគ្គលិកបម្រើសេវាស្ថានបេសកកម្មការទូត<br>និងកុងស៊ុលនៅក្រៅប្រទេស<br>៩- អង្គរក្សអមដំណើរគណៈប្រតិភូថ្នាក់ដឹកនាំ<br>ជាន់ខ្ពស់នៃព្រឹទ្ធសភា រដ្ឋសភានិងរាជរដ្ឋា-<br>ភិបាល។<br>១០-លិខិតឆ្លងដែនផ្លូវការប្រគេនមន្ត្រីសង្ឃទាំង<br>ពីរគណៈចាប់ពីអនុគណឡើងទៅ។ |
| **៦៧- លិខិតប្តូរសារ**<br>អ. exchange of notes<br>បារ. échange ( m. )<br>des notes ( f. ) | លិខិតព្រមព្រៀងរវាងភាគីរដ្ឋនានា ដែលមានលក្ខណៈមិនដូចកិច្ចព្រមព្រៀងឬសន្ធិសញ្ញាទេ។ លិខិតប្តូរសារអាចជាការព្រមព្រៀងរវាងរដ្ឋនិងរដ្ឋមុនពេលសម្រេចធ្វើកិច្ចព្រមព្រៀងឬសន្ធិសញ្ញានៅជំហានបន្ទាប់ទៀត។<br>ឧ. អ្នកតំណាងឱ្យរដ្ឋមួយសរសេរលិខិតប្តូរសារផ្ញើទៅរដ្ឋមួយទៀត ក្នុងលិខិតនោះ ម្ចាស់លិខិតលើកឡើងពីខទាំងឡាយដែលខ្លួនមានបំណងចង់បង្កើតឡើង។ ប្រសិនបើភាគីម្ខាងទៀតយល់ព្រមតាមខទាំងឡាយនោះ គេនឹងឆ្លើយតបជាលិខិតប្តូរសារមួយមកវិញ។ |
| **៦៨- វិទ្យាសាស្ត្រ<br>នយោបាយ**<br>អ. political science | វិទ្យាសាស្ត្រសង្គមមួយបែបដែលសិក្សាជាប្រព័ន្ធអំពីជីវិតសង្គមនយោបាយនិងអំពីគ្រប់បាតុភូតនយោបាយទាំងអស់ដែលកើតមានឡើង ពោល |

| | |
|---|---|
| បារ. science politique (f.) | គឺទំនាក់ទំនងរវាងស្ថាប័ននយោបាយនិងអង្គការនយោបាយ ដែលក្នុងនោះ មានរដ្ឋាភិបាល គណបក្សនយោបាយ អង្គការសង្គមនានា។<br>ឧ. នៅប្រទេសរុស្ស៊ី វិទ្យាសាស្ត្រនយោបាយបានក្លាយជាវិទ្យាសាស្ត្រឯករាជ្យមួយនៅចុងសតវត្សរ៍ទី២០។ |
| **៦៩- វិសោធនកម្ម**<br>អ. amendment<br>បារ. amendement (m.) | ការកែប្រែឬបន្ថែមទៅលើបទដ្ឋាននិងមាត្រានៃច្បាប់រដ្ឋធម្មនុញ្ញ ដូចជា ច្បាប់អន្តរជាតិឬរដ្ឋធម្មនុញ្ញ និង ច្បាប់ក្នុងស្រុកមួយឬច្រើន។<br>ឧ. រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នៃព្រះរាជាណាចក្រកម្ពុជាត្រូវបានធ្វើវិសោធនកម្មប្រាំមួយលើក។ ការធ្វើវិសោធនកម្មលើកទី១គឺកែប្រែមាត្រា២៨ ដែលត្រូវបានអនុម័តនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤។ លើកទី២ នៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៩។ លើកទី៣ នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០១។ លើកទី៤ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៤។ លើកទី៥ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៥ និង លើកទី៦ នៅ ថ្ងៃទី២ ខែមីនា ឆ្នាំ២០០៦។ |
| **៧០- វៀតកុង**<br>អ. vietcong<br>បារ. viet-cong | យុទ្ធជនកុម្មុយនីស្តដែលតស៊ូនៅប្រទេសវៀត-ណាមខាងត្បូងក្នុងចន្លោះឆ្នាំ១៩៥៤-១៩៧៥។ |

| | |
|---|---|
| **៧១- វៀតមិញ**<br>អ. vietminh<br>បារ.viet-minh | រណសិរ្សទាមទារឯករាជ្យវៀតណាមដែលបង្កើតឡើងដោយ ហូ ជីមិញ នៅឆ្នាំ១៩៤១។ រណសិរ្សនេះប្រមូលផ្ដុំជនកុម្មុយនីស្ត និង អ្នកជាតិនិយម ហើយ កំណត់គោលដៅដេញជន-ជាតិជប៉ុននិងបារាំងចេញពីប្រទេសវៀតណាម។ |
| **៧២- សង្គ្រាមចៃដន្យ**<br>អ. accidental war<br>**បារ.** guerre accidentelle ( f. ) | <u>**ន័យទី១**</u> ៖ សង្គ្រាមដែលកើតឡើងដោយថាហេតុឥតគ្រោងទុកផ្អែកលើមូលដ្ឋានពីរ -ទី១ កំហុសខាងបច្ចេកទេស និង -ទី២ ការយល់ខុស ឬ ការវាយតម្លៃស្ថានភាពខុស។<br><u>**ន័យទី២**</u> ៖ ការវាយតម្លៃខុសខាងផ្នែកការទូតនិងយោធា ដែលកំហុសនេះនាំទៅរកស្ថានការណ៍អាក្រក់ និង ធ្វើឱ្យមានការព្យាករខុសទៅលើលទ្ធផលនៃចំណាត់ការយោធា។ |
| **៧៣- សង្គ្រាមត្រជាក់**<br>អ. cold war<br>បា. guerre froide ( f. ) | ការប្រឈមមុខតឹងតែងលើវិស័យការទូត សេដ្ឋ-កិច្ច ចិត្តសាស្ត្រច្រើនជាងការប្រើអាវុធរវាងក្រុមប្រទេសសេរីនិយមឬមូលធននិយមនិងប្រទេសសង្គមនិយមឬកុម្មុយនីស្ត ក្រោយសង្គ្រាមលោកលើកទី២។ |
| **៧៤- សញ្ជាតិ**<br>**អ.** nationality<br>បារ. nationalité ( f. ) | ចរិតឬលក្ខណៈរបស់ប្រជាជាតិមួយដែលរស់នៅរួមគ្នាក្នុងក្របខណ្ឌនៃសហគមន៍មួយ ដែលមានទឹកដី ភាសា ទំនៀមទម្លាប់និងសេចក្ដីប៉ងប្រាថ្នារួម។ លក្ខណៈពិសេសនៃសញ្ជាតិរបស់ប្រជាជាតិមួយអាចកើតមានឡើងតាមរយៈកំណើតឬធម្ម- |

| | |
|---|---|
| | ជាតិនីយកម្ម សញ្ជាតូបនីយកម្ម អត្តសញ្ញាណ-កម្ម អាពាហ៍ពិពាហ៍ ការសុំកូនមកចិញ្ចឹម នីតិ-នីយកម្មនិងការផ្ទេរការគ្រប់គ្រងដែនដីពីរដ្ឋមួយទៅរដ្ឋមួយទៀត។<br>ឧ. នៅក្នុងសម័យកាលសង្គ្រាមនៃប្រទេសកម្ពុជាពីឆ្នាំ១៩៧០-១៩៧៩ ប្រជាជនខ្មែរមួយចំនួនបានភៀសខ្លួនទៅរស់នៅបរទេស ដូចជា ប្រទេសបារាំង អាម៉េរិក អូស្ត្រាលី។ល។ ហើយ ក្រោយមកពួកគេបានទទួលសញ្ជាតិបារាំង អាម៉េរិកនិងអូស្ត្រាលី តាមរយៈនីតិនីយកម្ម។ |
| **៧៥- សន្ធិសញ្ញា**<br>អ. treaty<br>បារ. traité ( m. ) | កិច្ចព្រមព្រៀងអន្តរជាតិដែលធ្វើឡើងរវាងរដ្ឋនិងរដ្ឋ នៅក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ហើយស្ថិតនៅក្រោមច្បាប់អន្តរជាតិ។ វាជាកិច្ចព្រមព្រៀងរវាងភាគីពីរឬច្រើន ដែលជាប្រធាននៃនីតិអន្តរជាតិសំដៅបង្កើតឱ្យមានឥទ្ធិពលខាងផ្លូវច្បាប់ និង ស្ថិតនៅក្រោមច្បាប់អន្តរជាតិ។ សន្ធិសញ្ញាត្រូវធ្វើឡើងដោយស្ម័គ្រចិត្តពីភាគីទាំងអស់ ដែលក្នុងន័យនេះ សន្ធិសញ្ញាអាចត្រូវបានចាត់ទុកជាកិច្ចសន្យាគតិយុត្ត ដែលមានអានុភាពអនុវត្តតាមផ្លូវច្បាប់ជាលក្ខណៈបង្ខំចំពោះគ្រប់ភាគីទាំងអស់ហើយ ដែលមានភាពខុសប្លែកពីសេចក្តីប្រកាសធម្មតា។ |

| | |
|---|---|
| | ឧ. សន្ធិសញ្ញាសន្តិភាពទីក្រុងវែកសៃ(Versailles) ឆ្នាំ១៩១៩គឺជាសន្ធិសញ្ញាមួយដែលបានបញ្ចប់សង្គ្រាមលោកលើកទី១(១៩១៤-១៩១៨) ជាផ្លូវការ។ សន្ធិសញ្ញានេះបានបង្កើតសង្គមប្រជាជាតិដែលបានកំណត់ពីសិទ្ធិកាតព្វកិច្ចរបស់មហាអំណាចដែលឈ្នះនិងចាញ់សង្គ្រាម និងបានបង្កើតប្រព័ន្ធចាប់បង្ខំមួយ ដែលតាមរយៈនេះ ប្រជាជាតិរីកចម្រើនទទួលបានការគ្រប់គ្រងស្របច្បាប់ទៅលើប្រជាជនដែលស្ថិតនៅក្រោមអាណានិគមរបស់ខ្លួន។ |
| **៧៦- សារតាំង**<br>អ. credentials<br>បារ. lettres (f.)<br>de créance (f.) | លិខិតដែលប្រមុខរដ្ឋនៃរដ្ឋមួយផ្តល់ជូនឯកអគ្គ-រដ្ឋទូតរបស់ខ្លួនដើម្បីប្រគល់ជូនប្រមុខរដ្ឋនៃប្រទេសដែលស្ថានទូតរបស់ខ្លួនតាំងនៅ។ |
| **៧៧- សិទ្ធិស្វ័យសម្រេច**<br>អ. autodetermination<br>បារ. autodétermination (f.) | សិទ្ធិក្នុងការសម្រេចចិត្តដោយឯករាជ្យរបស់បុគ្គល ក្រុម សហគមន៍ ស្ថាប័ន ឬ ប្រទេសណាមួយ។<br>ឧ. ស្របតាមស្មារតីរដ្ឋធម្មនុញ្ញនៃព្រះរាជាណា-ចក្រកម្ពុជាឆ្នាំ១៩៩៣ ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិស្វ័យសម្រេចក្នុងការជ្រើសរើសតំណាងរាស្ត្រដែលខ្លួនពេញចិត្ត។<br>ឧ. នៅឆ្នាំ២០០២ ប្រជាជនទីម័រខាងកើតបានប្រើប្រាស់សិទ្ធិស្វ័យសម្រេចក្នុងការបង្កើតរដ្ឋឯក-រាជ្យមួយដោយខ្លួនឯង។ |

| | |
|---|---|
| **៧៨- សេចក្ដីប្រកាសអន្តរជាតិ**<br>អ. international declaration<br>បារ. déclaration internationale ( f. ) | លិខិតូបករណ៍អន្តរជាតិផ្សេងៗដែលមានលក្ខណៈវិនិច្ឆ័យ ដូចជា៖<br>១- រាល់សេចក្ដីប្រកាសមិនអាចចងភ្ជាប់ជាកាតព្វកិច្ចតាមផ្លូវច្បាប់ទាំងអស់នោះទេ<br>២- សេចក្ដីប្រកាសគឺគ្រាន់តែចង់បង្ហាញឱ្យដឹងពីគោលបំណងអ្វីមួយរបស់ភាគីណាមួយ<br>៣- ក្នុងករណីមួយចំនួនមានសេចក្ដីប្រកាសខ្លះអាចមានឥទ្ធិពលចំពោះការអនុវត្តជាអន្តរ-ជាតិ ហើយ អាចចងភ្ជាប់កាតព្វកិច្ចជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង ច្បាប់អន្តរជាតិទូទៅ ក្នុងដំណាក់កាលក្រោយមកទៀត។<br>ឧ. - សេចក្ដីប្រកាសសកលស្ដីពីសិទ្ធិមនុស្សក្រោយមកបានក្លាយជាច្បាប់អន្តរជាតិដែលចងភ្ជាប់ប្រជាជាតិទាំងឡាយឱ្យគោរពតាម។<br>- សេចក្ដីប្រកាសស្ដីពីព្រែកជីកស៊ុយអេ និងការរៀបចំដើម្បីអនុវត្ត នៅឆ្នាំ១៩៥៧។ |
| **៧៩- ស្ដាំនិយម**<br>អ. rightism<br>បារ. droitisme ( m. ) | និន្នាការឬមនោគមវិជ្ជានយោបាយដែលនិយមការរក្សាទុកឬអភិរក្ស ការបែងចែកអំណាចនិងទ្រព្យសម្បត្តិ តាមរយៈប្រព័ន្ធដែលមានស្រាប់ឬការបែរទៅរកការគ្រប់គ្រងតាមបែបប្រពៃណី។ គេអាចកំណត់ថា ស្ដាំនិយមបាន តាមរយៈការដឹកនាំសង្គម ការគ្រប់គ្រងរដ្ឋ សេដ្ឋកិច្ច និង |

| | |
|---|---|
| | នយោបាយ តាមបែបខាងលើ។<br>៤. ក្នុងអំឡុងសតវត្សរ៍ទី១៩ ការបែងចែកនិន្នា-ការឆ្វេងនិយមនិងស្តាំនិយម គឺសំដៅលើការបែងចែករវាងអ្នកគាំទ្ររបបសាធារណរដ្ឋនិយម និង អ្នកគាំទ្ររបបរាជានិយម។ |
| **៨០- ស្ថានកុងស៊ុល**<br>អ. consulate<br>បារ. consulat ( m. ) | ការិយាល័យដែលបង្កើតឡើងដោយរដ្ឋមួយនៅក្នុងរាជធានីឬទីក្រុងសំខាន់ៗរបស់រដ្ឋមួយទៀត ក្នុងគោលបំណងជួយគាំទ្រនិងការពារប្រជា-ពលរដ្ឋរបស់គេក្នុងការធ្វើដំណើរ និង ស្នាក់នៅទីនោះ។ ការិយាល័យនេះទទួលបន្ទុកលើការងាររដ្ឋបាលសំខាន់ៗនានា ដូចជា ការចេញទិដ្ឋាការឱ្យប្រជាពលរដ្ឋនៅក្នុងប្រទេសនោះ ដែលមានបំណងធ្វើដំណើរទៅប្រទេសស្ថានកុងស៊ុលតំណាងនោះ។ ស្ថានកុងស៊ុលទាំងអស់ ទោះបីជានៅតាមរាជធានី ឬ ទីក្រុងសំខាន់ៗនានាក៏ដោយ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឯកអគ្គរដ្ឋទូត ឬ ស្ថានទូតរបស់ប្រទេសសាមី។ |
| **៨១- ស្ថានទូត**<br>អ. embassy<br>បារ. ambassade ( f. ) | ១- ការិយាល័យឬនិវេសនដ្ឋានផ្លូវការរបស់អគ្គរដ្ឋទូតនៅបរទេស។<br>២- គោលជំហរ( ឥរិយាបថ ) មុខងារឬការងាររបស់អគ្គរដ្ឋទូត។<br>៣- បេសកកម្មការទូត ដែលដឹកនាំដោយអគ្គ-រដ្ឋទូត។ |

| | |
|---|---|
| | ៤- អគ្គរដ្ឋទូតនិងបុគ្គលិករបស់គាត់។<br>៥- មនុស្សមួយក្រុមដែលគេបញ្ជូនឱ្យទៅ<br>បំពេញបេសកកម្មការទូតនៅឯបរទេស។ |
| **៨២- ស្វ័យគ្រប់គ្រង**<br>អ. self-goverment<br>បារ. libre-administration<br>( f. ) | របៀបគ្រប់គ្រងដោយស្វយ័តរបស់បុគ្គល គ្រួសារ សហគមន៍ អង្គការស្ថាប័ន សហគ្រាស។<br>ឧ. អគ្គិសនីកម្ពុជាទទួលបានស្វ័យគ្រប់គ្រងពីរាជរដ្ឋាភិបាលកម្ពុជា។ |
| **៨៣- ស្វ័យធនភាព**<br>អ. autarky<br>បារ. autarcie ( f. ) | ប្រព័ន្ធសេដ្ឋកិច្ចបិទជិតនៃប្រទេសមួយដែលមានការគ្រប់គ្រងដោយខ្លួនឯង ហើយ រស់នៅដោយពឹងផ្អែកលើធនធានរបស់ខ្លួនផ្ទាល់។<br>ឧ.ក្រោយវិបត្តិសេដ្ឋកិច្ចពិភពលោកឆ្នាំ១៩២៩ ម៉ូសូលីនីបានអនុវត្តនយោបាយស្វ័យធនភាពនៅប្រទេសអ៊ីតាលី។ |
| **៨៤- ស្វាស៊ីបាយលាបមាត់ពពែ** | ល្បិចកលរបស់អ្នកនយោបាយឬក្រុមណាមួយដែលបំភាន់ការពិត ដោយយកកំហុសរបស់ខ្លួនទៅទម្លាក់ដាក់ឱ្យអ្នកដទៃដែលមិនបានប្រព្រឹត្តកំហុសនោះ។ |
| **៨៥- ហ្វាស៊ីសនិយម**<br>អ. fascism<br>បារ. fascisme ( m. ) | លទ្ធិឬប្រព័ន្ធនយោបាយដែលនាំទៅដល់ការបង្កើតរបបផ្ដាច់ការជាតិនិយមជ្រុល ការក្ដាប់អំណាចដោយក្រុមអ្នកជំនួញ ដែលដឹកនាំដោយមូសូលីនី នៅក្នុងឆ្នាំ១៩២២ នៅប្រទេសអ៊ីតាលី។ |

| | |
|---|---|
| **៨៦- អគ្គរដ្ឋទូត / អគ្គរាជទូត(ឯកអគ្គរដ្ឋទូត/ឯកអគ្គរាជទូត)**<br>អ. ambassador<br>បារ. ambassadeur (m.) | អ្នកតំណាងខាងការទូតរបស់រដ្ឋមួយនៅបរទេស ដែលមានតំណែង(ឋានន្តរសក្តិ)ខ្ពស់ជាងគេបំផុត។<br>ឧ. ពីឆ្នាំ២០០៥ដល់២០០៨ ឯកឧត្តម ជូសេព ម៉ូសូមីលី(Joseph Mousomely) ជាឯកអគ្គ-រដ្ឋទូតសហរដ្ឋអាម៉េរិកប្រចាំព្រះរាជាណាចក្រកម្ពុជា ។ |
| **៨៧- អង្គការលើកលែងទោសអន្តរជាតិ**<br>អ. amnesty international<br>បារ. amnistie internationale (f.) | អង្គការនេះធ្វើយុទ្ធនាការអន្តរជាតិក្នុងការគាំទ្រចំពោះអ្នកទាំងឡាយណាដែលជាប់ឃុំឃាំងដោយជំនឿខាងសាសនា និង នយោបាយទូទាំងពិភពលោក។ អង្គការនេះបានអនុវត្តនូវគោលនយោបាយសំខាន់ៗចំនួនបី ៖<br>- ទីមួយ៖ ដោះលែងអ្នកទោសមនសិការ<br>- ទីពីរ៖ បញ្ឈប់ការធ្វើទារុណកម្មរាល់ទម្រង់ទាំងអស់ រួមទាំងទោសប្រហារជីវិត<br>- ទីបី៖ ស្វែងរកយុត្តិធម៌និងភាពត្រឹមត្រូវក្នុងការកាត់សេចក្តីចំពោះអ្នកទោសនយោបាយទាំងអស់។<br>អង្គការនេះមានទីតាំងនៅក្រុងឡុងដ៍ប្រទេសអង់គ្លេស មានតំណាងនៅអង្គការសហប្រជា-ជាតិ ហើយ បានទទួលពានរង្វាន់សិទ្ធិមនុស្សអង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៧៨។ អង្គការនេះទទួលស្គាល់ជាផ្លូវការដោយសហភាពអឺរ៉ុប |

| | |
|---|---|
| | ក្រុមប្រឹក្សានៃអឺរ៉ុប អង្គការនៃរដ្ឋអាម៉េរិកនិងអង្គ-ការឯកភាពអាហ្វ្រិក និង ក្នុងឆ្នាំ១៩៧៧ អង្គការនេះបានទទួលពានរង្វាន់ណូបែលសន្តិភាព។ |
| **៨៨- អធិការបតី**<br>អ. chancellor<br>បារ. chancelier ( m. ) | ប្រមុខរដ្ឋាភិបាលនៃប្រទេសមួយចំនួន។<br>ឧ. ប្រមុខដឹកនាំរដ្ឋាភិបាលនៃប្រទេសអាល្លឺម៉ង់មានងារជាអធិការបតី។ |
| **៨៩- អធិបតេយ្យភាព**[1]<br>អ. sovereignty<br>បារ. souveraineté ( f. ) | អំណាចខ្ពស់បំផុតនៅក្នុងរដ្ឋដែលមានសិទ្ធិគ្រប់គ្រង កំណត់និងត្រួតពិនិត្យកិច្ចការនានារបស់រដ្ឋដោយគ្មានការជ្រៀតជ្រែកពីអ្នកដទៃ។<br>អធិបតេយ្យភាពនៃរដ្ឋមួយមានទិដ្ឋភាពពីរ គឺ ទិដ្ឋភាពខាងក្នុងនិងទិដ្ឋភាពខាងក្រៅ។ ទិដ្ឋភាពខាងក្នុង គឺរដ្ឋមានអំណាចពេញលេញក្នុងការគ្រប់គ្រងប្រជាជនទាំងអស់នៅក្នុងរដ្ឋ។ ទិដ្ឋភាពខាងក្រៅ គឺរដ្ឋមានឯករាជ្យភាពឬមិនចំណុះការគ្រប់គ្រងរបស់បរទេសនិងទាមទារឱ្យមានការ |

[1] ក្នុងវចនានុក្រមខ្មែររៀបរៀងដោយសម្ដេចព្រះសង្ឃរាជ ជួន ណាត ព្រះអង្គបញ្ជាក់ថា "(...)កុំប្រើជា ***អធិបតេយ្យភាព*** ឡើយ ដ្បិត ***អធិបតេយ្យ*** ប្រែថា " ភារៈឬភាពនៃ...ជាអធិបតី " ដូចគ្នានឹង ***អធិបតិភាព*** ដែរស្រេចទៅហើយ,(...)"។ ប៉ុន្តែបើយើងសង្កេតទៅលើវចនានុក្រមដដែលនេះ យើងឃើញថា ពាក្យដែលជានាមសព្ទមួយចំនួន ដូចជា ***ការុញ្ញ*** (សេចក្ដីអាណិតអាសូរ) ***សាមគ្គី*** (សេចក្ដីព្រមព្រៀង) ... ត្រូវបានអនុញ្ញាតឱ្យប្រើជា ***ការុញ្ញភាព*** (ភាពនៃចិត្តដែលមានករុណា) ***សាមគ្គីភាព*** (ភាពនៃសាមគ្គី) ... បាន។ ក្នុងភាសាខ្មែរបច្ចុប្បន្ន ពាក្យ "**តម្លាភាព**" ដែលមានន័យចំថា ***ភាពនៃភាពថ្លា*** ត្រូវបានគេប្រើក្នុងន័យថា ***ភាពថ្លា*** ។

ដោយយោងទៅលើសេចក្ដីខាងលើនេះ កាលពីថ្ងៃពុធ ទី២១ ខែឧសភា ឆ្នាំ២០១៤ ក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.)បានអនុម័តឱ្យប្រើពាក្យ ***អធិបតេយ្យភាព*** ដោយមានសំឡេងគាំទ្រ២០សំឡេង និង មិនគាំទ្រ៥សំឡេង។ រីឯពាក្យ "**អធិបតីភាព**" វិញ ក.ជ.ភ.ខ.ប្រើក្នុងន័យដែលត្រូវនឹងភាសាបារាំងថា "(sous) la présidence de ..." សម្រាប់ការប្រជុំណាមួយ។

| | |
|---|---|
| | ទទួលស្គាល់ពីរដ្ឋដទៃ។<br>ឧ. ក្រោយពីបានទទួលឯករាជ្យពីបារាំង នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ប្រទេសកម្ពុជាមានអធិបតេយ្យភាពពេញលេញ។ |
| **៩០- អនុសញ្ញាអន្តរជាតិ**<br>អ. international convention<br>បារ. convention internationale( f. ) | ជាទូទៅ ន័យនៃពាក្យអនុសញ្ញាអន្តរជាតិមានលក្ខណៈដូចគ្នានឹងន័យរបស់ពាក្យសន្ធិសញ្ញាដែរ។ លក្ខណវិនិច្ឆ័យនៃអនុសញ្ញាគឺ ៖<br>- អនុសញ្ញាមានន័យនិងចាត់ទុកដូចជាច្បាប់សន្មត( ច្បាប់មានលក្ខណៈទូទៅនិងមានភាពប្រាកដប្រជាដែលត្រូវបានប្រជាជាតិទាំងឡាយលើសាកលលោកសុខចិត្តទទួលយកថា ជាកាតព្វកិច្ចខាងផ្លូវច្បាប់ )។<br>- អនុសញ្ញាត្រូវបើកឱ្យមានការចូលរួមពីសំណាក់សហគមន៍អន្តរជាតិទាំងមូលឬពីបណ្តារដ្ឋនានាមួយចំនួនធំ។<br>ឧ. អនុសញ្ញាស្តីពីការទប់ស្កាត់និងការដាក់ទណ្ឌកម្មនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឆ្នាំ១៩៥១អនុសញ្ញាស្តីពីច្បាប់សមុទ្រ អនុសញ្ញាស្តីពីបុព្វសិទ្ធិ និង អភ័យឯកសិទ្ធិរបស់អង្គការសហប្រជាជាតិឆ្នាំ១៩៤៦ អនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងការទូតឆ្នាំ១៩៦១។ |

| | |
|---|---|
| **៩១- អនុស្សរណៈនៃការយោគយល់គ្នា**<br>អ. memorandum of understanding<br>បារ. mémorandum (m.) d' entente (f.) | លិខិតូបករណ៍អន្តរជាតិទាំងឡាយណា ដែលមានទម្រង់ជាលិខិតទោល ហើយ មិនតម្រូវឱ្យមានការផ្តល់សច្ចាប័ន។<br>ឧ. អនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃស្តីពីការវាស់វែងនិងខណ្ឌព្រំសីមាព្រំដែនគោក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ២០០០ ។ |
| **៩២- អន្តរាគមន៍ការទូត**<br>អ. diplomatic intervention<br>បារ. intervention diplomatique (f.) | អន្តរាគមន៍មួយដែលត្រូវបានធ្វើឡើងដោយអង្គការសហប្រជាជាតិឬអង្គការអន្តរជាតិនៅពេលមានជម្លោះអន្តរជាតិកើតឡើង។ អន្តរាគមន៍នេះមិនមានប្រើអំពើហិង្សាដូចអន្តរាគមន៍យោធាទេ ហើយមានទម្រង់ចំនួន៤ ដូចខាងក្រោម ៖<br>១- ការអង្កេត(inquiry)៖ ការស្វែងរកការពិតដោយអ្នកអង្កេតការណ៍អព្យាក្រឹត។<br>២- ការសម្របសម្រួល(good offices)៖ ការលើកទឹកចិត្តភាគីនានាឱ្យចរចាគ្នាដោយប្រកាន់ជំហរអព្យាក្រឹតក្នុងការចរចា។<br>៣- សន្ធានកម្ម(Mediation)៖ ការស្នើឡើងជាដំណោះស្រាយដោយធ្វើជាអន្តរការីរវាងភាគីទាំងសងខាង។ ភ្នាក់ងារនេះមានតួនាទីសម្របសម្រួលឱ្យមានដំណោះស្រាយដោយសន្តិវិធី ប៉ុន្តែគ្មានអំណាចចាប់បង្ខំឱ្យភាគី |

| | |
|---|---|
| | ជម្លោះទទួលយកដំណោះស្រាយរបស់ខ្លួនឡើយ។<br>តួនាទីរបស់អ្នកសម្របសម្រួលគឺគ្រាន់តែផ្តល់ឱវាទតែប៉ុណ្ណោះ។<br>៤- ការសម្រុះសម្រួល( conciliation )៖ នីតិវិធីដែលត្រូវបានបង្កើតឡើងដោយគណៈកម្មការមួយដែលទទួលបានការទុកចិត្តនិងមានការឯកភាពពីភាគីជម្លោះដើម្បីតម្រង់ទិសភាគីនានាក្នុងការស្វែងរកដំណោះស្រាយមួយដែលមិនចងកាតព្វកិច្ច និង ដើម្បីផ្សះផ្សាជម្លោះរវាងភាគីនានា។ |
| **៩៣- អព្យាក្រឹតនិយម**<br>អ. neutralism<br>បារ. neutralisme( m. ) | លទ្ធិឬប្រព័ន្ធនយោបាយដែលប្រទេសមួយប្រកាន់យកគោលការណ៍អព្យាក្រឹតក្នុងទំនាក់ទំនងជាមួយប្រទេសណាមួយ ឬ ក្រុមប្រទេសណាមួយក្នុងគោលបំណងគេចពីការជ្រៀតជ្រែករបស់ប្រទេសមហាអំណាចនិងដើម្បីរក្សាសន្តិភាព។ លទ្ធិនេះបាននាំមកដល់ការបង្កើតចលនាមិនចូលបក្សសម្ព័ន្ធ។ |
| **៩៤- អភ័យឯកសិទ្ធិការទូត**<br>អ. diplomatic immunity<br>បារ. immunité diplomatiques( f. ) | សិទ្ធិទាំងឡាយដែលរដ្ឋម្ចាស់ផ្ទះផ្តល់ឱ្យដល់ស្ថានបេសកកម្មការទូតនិងបុគ្គលិកទាំងឡាយរបស់បេសកកម្មការទូតនោះឱ្យរួចផុតពីអំណាចយុត្តាធិការរបស់រដ្ឋម្ចាស់ផ្ទះដោយធានានូវភាពពុំអាចបំពារបំពានបាន និង ការពារដល់ការអនុវត្តមុខងាររបស់បុគ្គលិកទាំងនោះ។ |

| | |
|---|---|
| **៩៥- អភ័យឯកសិទ្ធិ ដាច់ខាតការទូត**<br>អ. absolute diplomatic immunity<br>បារ. immunité diplomatique absolue ( f. ) | អភ័យឯកសិទ្ធិពុំមែនត្រឹមតែមិនអនុញ្ញាតឱ្យមានការកាត់ទោសឬការអនុវត្តសាលក្រមទៅលើអ្នកការទូតប៉ុណ្ណោះទេ ថែមទាំងបានហាមឃាត់ការចាប់ផ្ដើមនូវនីតិវិធីព្រហ្មទណ្ឌចំពោះអ្នកការទូតផងដែរ ដូចជា ការចេញដីកាកោះអញ្ជើញអ្នកការទូតឱ្យមកចូលរួមការជំនុំជម្រះក្ដីឬកោះអញ្ជើញឱ្យមកធ្វើជាកសិណសាក្សីជាដើម។ |
| **៩៦- អាណានិគម**<br>អ. colony<br>បារ. colonie ( f. ) | ប្រទេសឬតំបន់មួយដែលត្រូវបានគ្រប់គ្រងដោយប្រទេសផ្សេងមួយទៀតដែលមានអំណាចខ្លាំងជាង។<br>ឧ. ប្រទេសកម្ពុជាធ្លាប់ជាអាណានិគមរបស់ប្រទេសបារាំងពីឆ្នាំ១៨៨៤ដល់ឆ្នាំ១៩៥៣។ |
| **៩៧- អាណានិគមនិយម**<br>អ. colonialism<br>បារ. colonialisme ( m. ) | ទម្រង់ដោយឡែកមួយនៃប្រព័ន្ធនយោបាយ ឬលទ្ធិនិងការអនុវត្តជាក់ស្ដែង ដែលនៅក្នុងនោះមហាអំណាចមានលក្ខណៈរឹងប៉ឹងទៅបានដោយសារការឈ្លានពាន ការកាន់កាប់ទឹកដីនិងប្រជាជននៃប្រទេសដែលគេហៅថាប្រទេសអាណានិគម។<br>ឧ. នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ បារាំងបានដាក់អាណាព្យាបាលនៅប្រទេសកម្ពុជាតាមរយៈការចុះនូវសន្ធិសញ្ញាជាមួយព្រះបាទនរោត្តម។ ក្រោយមកទៀត រូបភាពអាណាព្យា- |

| | |
|---|---|
| | បាលនេះត្រូវបានដូរមកជាអាណានិគមវិញ តាមរយៈការចុះសន្ធិសញ្ញាមួយថ្មីទៀត នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៨៨៤។ |
| **៩៨- អាណានិគមនិយមបែបថ្មី**<br>អ. neo-colonialism<br>បារ.néo-colonialisme (m.) | ទម្រង់ថ្មីនៃអាណានិគមនិយមដែលប្រើសម្ពាធផ្នែកសេដ្ឋកិច្ច នយោបាយ វប្បធម៌ឬសម្ពាធផ្សេងៗទៀត ដោយប្រទេសដែលមានអំណាចខ្លាំងជាងដើម្បីត្រួតត្រាឬមានឥទ្ធិពលទៅលើប្រទេសដែលមានការអភិវឌ្ឍតិចតួច។ |
| **៩៩- អាណាព្យាបាល**<br>អ. protectorate<br>បារ. protectorat (m.) | របបគតិយុត្តដោយសន្ធិសញ្ញាមួយដែលរដ្ឋឬទឹកដីមួយត្រូវបានដាក់ឱ្យនៅក្រោមការគ្រប់គ្រងនិងការការពារនៃរដ្ឋមួយទៀតដែលមានអំណាចខ្លាំងជាង។ រដ្ឋដែលនៅក្រោមអាណាព្យាបាលមានសិទ្ធិរក្សារដ្ឋាភិបាលឬរដ្ឋបាលរបស់ខ្លួនបាន។<br>ឧ. នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ បារាំងបានមកដាក់អាណាព្យាបាលនៅប្រទេសកម្ពុជាតាមរយៈការចុះសន្ធិសញ្ញាជាមួយនឹងព្រះបាទនរោត្តម។ |
| **១០០- ឧក្រិដ្ឋជនសង្គ្រាម**<br>អ. war criminal<br>បារ. criminel (m.) de guerre (f.) | ជនណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម។ |
| **១០១- ឯករាជ្យ**<br>អ. independence<br>បារ. indépendence(f.) | ភាពនៃរដ្ឋឬប្រទេសដែលមានសិទ្ធិនិងសេរីភាពពេញបរិបូរក្នុងការគ្រប់គ្រងប្រទេសខ្លួនឯង មិនចំណុះប្រទេសដទៃ។ |

| | |
|---|---|
| | ឧ. ប្រទេសកម្ពុជាបានទទួលឯករាជ្យពីប្រទេសបារាំងនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។ |
| **១០២- អំណាចតុលាការ**<br>អ. judiciary power<br>បារ. pouvoir judiciaire (m.) | អំណាចមួយក្នុងចំណោមអំណាចទាំងបីរបស់រដ្ឋដែលទទួលបន្ទុកជម្រះក្តី។<br>ឧ. មាត្រា១២៨ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣បានចែងថា អំណាចតុលាការជានារក្សាអនាគតិនិងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋ-បាលផង។ អំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និង សាលាជម្រះក្តីគ្រប់ផ្នែកនិងគ្រប់ជាន់ថ្នាក់។ |
| **១០៣-អំណាចនីតិបញ្ញត្តិ**<br>អ. legislative power<br>បារ. pouvoir législatif (m.) | - អំណាចក្នុងការតាក់តែងនិងអនុម័តច្បាប់។<br>ឧ. នៅក្នុងប្រទេសសេរី ពហុបក្ស ដូចនៅក្នុងប្រទេសកម្ពុជា អំណាចនីតិបញ្ញត្តិត្រូវបានប្រគល់ជូនរដ្ឋសភា និង ព្រឹទ្ធសភា។<br>- អំណាចរបស់ស្ថាប័នសភាដែលមានកាតព្វកិច្ចបង្កើតនិងអនុម័តច្បាប់។ នៅក្នុងប្រទេសកម្ពុជាអង្គការនីតិបញ្ញត្តិ(សភា)គឺមានរដ្ឋសភានិងព្រឹទ្ធសភា។<br>ឧ. មាត្រា៩០ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា រដ្ឋសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយ បំពេញភារកិច្ចរបស់ |

| | |
|---|---|
| | ខ្លួនដូចបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់ជាធរមាន និង តាមមាត្រា៩៩ថ្មីនៃរដ្ឋធម្មនុញ្ញបានចែងថា ព្រឹទ្ធសភាជាអង្គការដែលមាន អំណាចនីតិបញ្ញត្តិ ហើយ បំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់ជាធរមាន។ |
| **១០៤- អំណាចនីតិប្រតិបត្តិ**<br>អ. executive power<br>បារ. pouvoir exécutif (m.) | អំណាចមួយក្នុងចំណោមអំណាចទាំងបីរបស់រដ្ឋដែលទទួលបន្ទុកប្រតិបត្តិតាមច្បាប់និងអនុវត្តច្បាប់។<br>ឱ. នៅប្រទេសកម្ពុជា អំណាចនីតិប្រតិបត្តិសំដៅដល់គណៈរដ្ឋមន្ត្រីដែលជារាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង រដ្ឋលេខាធិការជាសមាជិក។ |
| **១០៥- អំពើប្រល័យពូជសាសន៍**<br>អ. genocide<br>បារ. génocide (m.) | អំពើមួយក្នុងចំណោមអំពើដូចខាងក្រោម ហើយ ដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុងឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនាណាមួយ ដូចជា៖<br>- ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម<br>- ការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញាសមាជិកនៃក្រុម<br>- ការធ្វើដោយចេតនាឱ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅមួយ ដែលរៀបចំឡើង |

| | |
|---|---|
| | សម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុងឬមួយផ្នែក<br>- ការដាក់នូវវិធានការនានា ដែលមានបំណងរារាំងមិនឱ្យមានការផ្តល់កំណើតទារក<br>- ការបញ្ជូនកុមារដោយបង្ខំពីក្រុមមួយទៅឱ្យក្រុមមួយទៀត។ |
| **១០៦- អ្នកការទូត**<br>អ. diplomat<br>បារ. diplomate | អ្នកដែលធ្វើការងារទាក់ទងទៅនឹងការទូត ហើយដែលត្រូវបានបញ្ជូនពីប្រទេសឬស្ថាប័នសាមីណាមួយដើម្បីទៅបំពេញការងារការទូតនៅបរទេស។<br>ឧ. លោក យ៉ាស៊ូស៊ី អាកាស៊ី ជាអ្នកការទូតតំណាងអង្គការសហប្រជាជាតិដែលមានបេសកកម្មសម្របសម្រួលការងារក្នុងការរៀបចំការបោះឆ្នោតសាកលតាមបែបប្រជាធិបតេយ្យនៅកម្ពុជាចាប់ពីឆ្នាំ១៩៩១ដល់១៩៩៣។<br>ឧ. លោកស្រី ម៉ាដឺលែន អលប្រាយ អតីតរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាម៉េរិកគឺជាអ្នកការទូតដ៏ល្បីល្បាញរបស់សហរដ្ឋអាម៉េរិកដែលទទួលបេសកកម្មក្នុងការបញ្ចុះបញ្ចូលសមាជិកអង្គការណាតូ(NATO)និងបណ្តាប្រទេសដែលពាក់ព័ន្ធឱ្យចូលរួមធ្វើសង្គ្រាមនៅប្រទេសយូហ្គោស្លាវីនៅឆ្នាំ១៩៩៧។ |

| | |
|---|---|
| **១០៧- អ្នកគាំទ្រនយោបាយ**<br>អ. political supporter<br>បារ. supporteur politique ( m. ) | ពលរដ្ឋទាំងឡាយណាដែលចូលរួមគាំទ្រ ដោយផ្ទាល់ក្តី ដោយប្រយោលក្តី ទាំងផ្នែកស្មារតីនិងសម្ភារៈចំពោះគណបក្សនយោបាយណាមួយដែលខ្លួនពេញចិត្ត។<br>ឧ. លទ្ធផលនៃការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ចំនួនអាសនៈដែលទទួលបានបញ្ជាក់ពីសំឡេងនៃអ្នកគាំទ្រនយោបាយ។ |
| **១០៨- អ្នកធ្វើនយោបាយ**<br>អ. political player<br>បារ. militant politique ( m. ) | ពលរដ្ឋទូទៅដែលមានគំនិត ទស្សនៈ ចក្ខុវិស័យមនោគមវិជ្ជានយោបាយ ហើយ ធ្វើសកម្មភាពនយោបាយ ក្នុងបំណងសម្រេចប្រយោជន៍អ្វីមួយរបស់ខ្លួន។<br>ឧ.សកម្មជនគណបក្សនយោបាយទាំងអស់ជាអ្នកធ្វើនយោបាយ។ |
| **១០៩- អ្នកនយោបាយ**<br>អ. politician<br>បារ. politicien ( m. ) | អ្នកធ្វើការទាក់ទងនឹងការងារនយោបាយឬជាអ្នកដោះស្រាយបញ្ហានយោបាយគ្រប់ប្រភេទដើម្បីបម្រើផលប្រយោជន៍សង្គមជាតិ។<br>ឧ. សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករដ្ឋាភិបាល ជាអ្នកនយោបាយ។ |
| **១១០- អ្នកនយោបាយផ្កាយរីកគ្រប់រដូវ** | អ្នកនយោបាយណាដែលយកទេពកោសល្យ សមត្ថភាព បច្ចេកទេស យុទ្ធវិធី យុទ្ធសាស្ត្រនិងទស្សនវិស័យ ដើម្បីសម្រេចបានជ័យជម្នះគ្រប់សម័យកាល។ |

| | |
|---|---|
| **១១១- អ្នកនយោបាយ ព្រះអាទិត្យ**<br>អ. sun politician | អ្នកនយោបាយទាំងឡាយណាដែលគ្រប់គ្រងអំណាច ហើយ នៅក្នុងកាលៈទេសៈណាមួយ ដែលបានបាត់បង់អំណាចនោះទៅ ក្នុងរយៈពេលក្រោយមកទៀត ក៏បានចាប់យកអំណាចមកវិញ។ អ្នកនយោបាយប្រភេទនេះ គេហៅថា អ្នកនយោបាយព្រះអាទិត្យ។ |
| **១១២- អ្នកនយោបាយ អស្ដង្គត** | ឥស្សរជននយោបាយទាំងឡាយណាដែលទទួលជោគជ័យក្នុងនយោបាយ ហើយ ក៏បរាជ័យទៅវិញ។<br>ឧ. របបកម្ពុជាប្រជាធិបតេយ្យដឹកនាំដោយ ប៉ុល ពត បានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ហើយ ប៉ុល ពត ក៏បញ្ចប់ជីវិតនយោបាយរបស់ខ្លួន។ |

បោះពុម្ពលើកទី១ ចំនួន ២ ០០០ច្បាប់
នៅរោងពុម្ព ស៊ី យូ
ផ្ទះលេខ ៣៥CEo មហាវិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ